# នៅចំពោះមុខអង្គជំនុំជម្រះតុលាការកំពូល
# នៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា


**ព័ត៌មានពិស្តារនៃការដាក់ឯកសារ**

| | | |
|---|---|---|
| សំណុំរឿងលេខ | : | ០០២/១៩-០៩-២០០៧-អវតក/អជតក |
| ដាក់ទៅ | : | អង្គជំនុំជម្រះតុលាការកំពូល |
| ថ្ងៃដាក់ | : | ថ្ងៃទី៦ ខែមិថុនា ឆ្នាំ២០១៣ |
| ភាគីអ្នកដាក់ | : | សហព្រះរាជអាជ្ញា |
| ភាសាដើម | : | អង់គ្លេស |

ឯកសារបកប្រែ
TRANSLATION/TRADUCTION
ថ្ងៃ ខែ ឆ្នាំ (Date): 06-Jun-2013, 15:12
CMS/CFO: Sann Rada

**ចំណាត់ថ្នាក់ឯកសារ**

ប្រភេទឯកសារដែលស្នើឡើងដោយភាគីដាក់ឯកសារ: សាធារណៈ

ចំណាត់ថ្នាក់ឯកសារកំណត់ដោយអង្គជំនុំជម្រះតុលាការកំពូល: សាធារណៈ/Public

ប្រភេទនៃចំណាត់ថ្នាក់ឯកសារ:

ការពិនិត្យចំណាត់ថ្នាក់ឯកសារបណ្តោះអាសន្នឡើងវិញ:

ឈ្មោះមន្ត្រីដែលបានពិនិត្យ:

ហត្ថលេខា:


---

## ចម្លើយតបរបស់សហព្រះរាជអាជ្ញា ទៅនឹងបណ្តឹងសាទុក្ខរបស់ ខៀវ សំផន ប្រឆាំងនឹង សេចក្តីសម្រេចលើសំណើសុំដោះលែងឲ្យនៅក្រៅឃុំជាបន្ទាន់ ដោយដាក់ឲ្យស្ថិតនៅក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការ

---


**អ្នកដាក់ឯកសារ:**

សហព្រះរាជអាជ្ញា:

លោកស្រី ជា លាង

លោក Andrew CAYLEY

**អ្នកទទួលឯកសារ:**

អង្គជំនុំជម្រះតុលាការកំពូល:

ចៅក្រម គង់ ស្រ៊ីម, ប្រធាន

ចៅក្រម A. KLONOWIECKA-MILART

ចៅក្រម សោម សិរីវឌ្ឍ

ចៅក្រម C. N. JAYASINGHE

ចៅក្រម ម៉ុង មុន្នីចរិយា

ចៅក្រម យ៉ា ណារិន

ចៅក្រម Florence Ndepele NUMBA

**ជនជាប់ចោទ:**

នួន ជា

ខៀវ សំផន

**មេធាវីការពារក្តីជនជាប់ចោទ:**

លោក សុន អរុណ

លោក Michiel PESTMAN

លោក Victor Koppe

លោក គង់ សំអុន

លោកស្រី Anta GUISSÉ

លោក Arthur VERCKEN

លោក Jacques VERGÈS

**<u>ចម្លងជូន:</u>**
**សហមេធាវីនាំមុខតំណាងដើមបណ្តឹង**
**រដ្ឋប្បវេណី:**
ពេជ អង្គ
Elisabeth SIMONNEAU FORT

## I. សេចក្តីផ្តើម

១- សហព្រះរាជអាជ្ញាសូមដាក់ជូនសេចក្តីសន្និដ្ឋានទាំងនេះ (“ចម្លើយតប”) ដើម្បីជាការឆ្លើយតបទៅនឹងបណ្តឹងសាទុក្ខ (“បណ្តឹងសាទុក្ខ”)[1] ដោយក្រុមមេធាវីការពារក្តីរបស់ ខៀវ សំផន (“មេធាវីការពារក្តី”) ប្រឆាំងនឹងសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងលើសំណើសុំរបស់មេធាវីការពារក្តី សុំដោះលែងជនជាប់ចោទឱ្យនៅក្រៅឃុំជាបន្ទាន់ (សេចក្តីសម្រេចដែលរងការជំទាស់)[2]។

២- ដូចដែលបានពន្យល់បន្ថែមខាងក្រោម សហព្រះរាជអាជ្ញាសន្និដ្ឋានថា បណ្តឹងសាទុក្ខនេះគួរតែត្រូវបានបដិសេធដោយធ្វើមិនទាន់ពេលវេលា ឬម្យ៉ាងទៀតថា ដោយសារការខកខានមិនបានបង្ហាញឱ្យឃើញច្បាស់អំពីកំហុសដែលស័ក្តិសមនឹងទទួលបាននូវដំណោះស្រាយ។ ជាពិសេសដើម្បីជាការឆ្លើយតបទៅនឹងមូលដ្ឋានផ្សេងៗ ក្នុងការដាក់បណ្តឹងសាទុក្ខដោយមេធាវីការពារក្តី សហព្រះរាអាជ្ញាសន្និដ្ឋានថា៖ (១) មេធាវីការពារក្តីមិនបានធ្វើការចង្អុលបង្ហាញភ័ស្តុតាងអំពីកំហុស ដែលស័ក្តិសមនឹងទទួលបាននូវដំណោះស្រាយដែលពាក់ព័ន្ធនឹងកត្តាទាំងឡាយដែលអង្គជំនុំជម្រះសាលាដំបូងបានពិចារណា នៅក្នុងការសម្រេចថា នឹងមានហានិភ័យអំពីការចូលរួមរបស់ ខៀវ សំផន (“ជនជាប់ចោទ”) នៅក្នុងពេលសវនាការ ដែលចាំបាច់គួរតែត្រូវបន្តការឃុំខ្លួនតទៅទៀត ឬថាស្ថានទម្ងន់ដែលមេធាវីបានផ្តល់ទៅលើកត្តាទាំងនោះ (២)មេធាវីការពារក្តីមិនបានចង្អុលបង្ហាញភ័ស្តុតាងទៅលើកំហុស ដែលគួរតែទទួលបាននូវដំណោះស្រាយ ទាក់ទងអំពីការវិភាគរបស់អង្គជំនុំជម្រះសាលាដំបូងដែលថា រយៈពេលនៃការឃុំខ្លួនមានភាពសមាមាត្រដោយបានពិនិត្យពិចារណាទៅលើកត្តាទាំងអស់ និង(៣) នៅក្នុងខណៈដែលអង្គជំនុំជម្រះឃើញហាក់ដូចជាបានមានកំហុសនៅក្នុងការពិចារណាថា ចាប់តាំងពីពេលដាក់សំណើរបស់ជនជាប់ចោទ ដើម្បីសុំដោះលែងឱ្យនៅក្រៅឃុំ ដោយអនុលោមតាមវិធាន៨២(៤) មក តើមានការប្រែប្រួលខាងកាលៈទេសៈដែរ ឬទេ? កំហុសណាមួយក៏ដោយ គឺមិនបានបណ្តាលឱ្យមានការខូចខាតឡើយ ព្រោះអង្គជំនុំជម្រះបានដឹកនាំធ្វើការពិនិត្យឡើងវិញ អំពីអង្គហេតុ និងកាលៈទេសៈទាំងអស់ ដែលទាក់ទងទៅនឹងការឃុំខ្លួនជនជាប់ចោទ។

---

[1] ឯកសារលេខ **E275/2/1** បណ្តឹងសាទុក្ខប្រឆាំងនឹងសេចក្តីសម្រេចលើសំណើរបស់ ខៀវ សំផន សុំដោះលែងឱ្យនៅក្រៅឃុំជាបន្ទាន់ដោយការដាក់ឱ្យស្ថិតនៅក្រោមការត្រួតពិនិត្យរបស់តុលាការ, ចុះថ្ងៃទី១៤ ឧសភា ២០១៣ (“បណ្តឹងសាទុក្ខរបស់ ខៀវ សំផន”)

[2] ឯកសារលេខ**E275/1** សេចក្តីសម្រេចលើសំណើរបស់ ខៀវ សំផន សុំដោះលែងឱ្យនៅក្រៅឃុំជាបន្ទាន់, ចុះថ្ងៃទី២៦ មេសា ឆ្នាំ២០១៣ ត្រង់កថាខណ្ឌទី២៣ (“ សេចក្តីសម្រេចដែលរងការជំទាស់”).

## II. ប្រវត្តិនីតិវិធី

៣- កាលពីថ្ងៃទី១៩ ខែវិច្ឆិកា ឆ្នាំ២០០៧ ខៀវ សំផន ត្រូវបានឃុំខ្លួនដោយដីកាសម្រេចរបស់សហចៅក្រមស៊ើបអង្កេត(“សចស”) និងត្រូវបានផ្ទេរបញ្ជូនមកកាន់មន្ទីរឃុំឃាំងរបស់ អវតក[3]។ សចស បានធ្វើដីកាសម្រេចឃុំខ្លួនជាថ្មីឡើងវិញយ៉ាងទៀងទាត់ទៅតាមពេលកំណត់ ដែលជាបន្ទាប់មកទៀត ត្រូវបានតម្កល់ដោយអង្គបុរេជំនុំជម្រះ[4]។

៤- កាលពីថ្ងៃទី១៥ ខែកញ្ញា ឆ្នាំ២០១០ សចស បានចេញដីកាដំណោះស្រាយរបស់ខ្លួន នៅក្នុងសំណុំរឿងលេខ០០២ និងបានចេញដីកាសម្រេចឲ្យបន្តឃុំខ្លួនជនជាប់ចោទជាបណ្តោះអាសន្នតទៅទៀត រហូតទល់ពេលជនជាប់ចោទត្រូវបាននាំមកបង្ហាញខ្លួននៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង ដែលក្នុងនោះនិយាយថា លក្ខខណ្ឌទាំងឡាយដូចចែងនៅក្នុងវិធាន៦៣(៣) នៃវិធានផ្ទៃក្នុង ដែលធ្វើយុត្តិកម្មចំពោះការឃុំខ្លួននេះត្រូវបានបំពេញសព្វគ្រប់ហើយ[5]។

៥- កាលពីថ្ងៃទី១៣ ខែមករា ឆ្នាំ២០១១ អង្គបុរេជំនុំជម្រះបានដាក់សេចក្តីសម្រេចរបស់ខ្លួនលើបណ្តឹងសាទុក្ខរបស់ជនជាប់ចោទប្រឆាំងនឹងដីកាដំណោះស្រាយ ដែលប្រកាសថាបណ្តឹងសាទុក្ខរបស់ជនជាប់ចោទមិនអាចទទួលយកបានទេ ហើយបង្គាប់ឲ្យបន្តការឃុំខ្លួនជនជាប់ចោទបណ្តោះអាសន្នតទៅទៀត រហូតទល់ពេលជនជាប់ចោទត្រូវបាននាំមកបង្ហាញខ្លួន នៅចំពោះមុខអង្គជំនុំជម្រះសាលា

[3] ឯកសារលេខ **C27** ដីកាសម្រេចស្តីពីការឃុំខ្លួន ខៀវ សំផន, ចុះថ្ងៃទី១៩ វិច្ឆិកា ២០០៧។

[4] *សូមអាន ឧទាហរណ៍ដូចជា* ឯកសារលេខ **C26/5/26** សេចក្តីសម្រេចលើបណ្តឹងសាទុក្ខរបស់ ខៀវ សំផន ប្រឆាំងនឹងដីកាសម្រេចបដិសេធនូវសំណើសុំដោះលែង និងដីកាសម្រេចបន្តការឃុំខ្លួនបណ្តោះអាសន្ន, ចុះថ្ងៃទី៣ កក្កដា ២០០៩, ត្រង់កថាខណ្ឌទី ៥៣,៥៨,និង៦៣។ ឯកសារលេខ **C26/9/12** សេចក្តីសម្រេចលើបណ្តឹងសាទុក្ខរបស់ ខៀវ សំផន ប្រឆាំងនឹងដីកាសម្រេចបន្តការឃុំខ្លួនបណ្តោះអាសន្ន, ចុះថ្ងៃទី៣០ មេសា ២០១០ ត្រង់កថាខណ្ឌទី៣៤,៣៥,៣៨, និងទី៣៩។

[5] ឯកសារលេខ **D427** ដីកាដំណោះស្រាយ, ចុះថ្ងៃទី១៥ កញ្ញា ២០១០ត្រង់កថាខណ្ឌទី១៦២២ (" ផ្នែកទីប្រាំមួយ: ការថែទាំជួសជុលមន្ទីរឃុំឃាំង")។

ដំបូង[6]។ កាលពីថ្ងៃទី២១ ខែមករា ឆ្នាំ២០១១ អង្គបុរេជំនុំជម្រះបានចេញសេចក្តីបញ្ជាក់មូលហេតុសម្រាប់ផ្នែកខ្លះនៃការសម្រេចឃុំខ្លួន[7]។

៦- អង្គជំនុំជម្រះសាលាដំបូងបានទទួលសំណុំរឿងលេខ០០២ នៅថ្ងៃទី១៣ ខែមករា ឆ្នាំ២០១១។ កាលពីថ្ងៃទី១៨ ខែមករា ឆ្នាំ២០១១ មេធាវីការពារក្តីបានដាក់សំណើមួយសុំដោះលែងជនជាប់ចោទឲ្យនៅក្រៅឃុំជាបន្ទាន់[8]។ សហព្រះរាជអាជ្ញាបានដាក់សេចក្តីសន្និដ្ឋានដោយផ្ទាល់មាត់មួយដើម្បីជាការឆ្លើយតប កាលពីថ្ងៃទី៣១ ខែមករា ឆ្នាំ២០១១[9]។ នៅថ្ងៃទី១៦ ខែកុម្ភៈ ឆ្នាំ២០១១ អង្គជំនុំជម្រះសាលាដំបូងបានច្រានចោលនូវសំណើនោះ និងបានចេញដីកាសម្រេចឲ្យបន្តការឃុំខ្លួនជនជាប់ចោទ ដោយអនុលោមតាមវិធាន៦៣(៣)(ខ)(iii)នៃវិធានផ្ទៃក្នុង ដោយផ្អែកលើមូលដ្ឋាននៃភាពចាំបាច់ ដើម្បីធានាឲ្យមានភាពប្រាកដអំពីវត្តមានរបស់ជនជាប់ចោទ នៅក្នុងអម្លុងពេលនៃកិច្ចដំណើការនីតិវិធីនៃការជំនុំជម្រះក្តី[10]។ អង្គជំនុំជម្រះក៏បានអនុញ្ញាតផងដែរ ជាដំណោះស្រាយមួយចំពោះការមិនផ្តល់នូវការព្រមានជាមុនថា សវនាការដោយផ្ទាល់មាត់អាចពាក់ព័ន្ធនឹងកត្តានានា នៅក្នុងវិធាន៦៣(៣)នៃវិធានផ្ទៃក្នុង ដែល "មិនតម្រូវឲ្យមេធាវីការពារក្តី បង្ហាញភ័ស្តុតាងអំពីការផ្លាស់ប្តូរកាលៈទេសៈ ដូចចែងនៅក្នុងវិធាន៨២(៤)នៃវិធានផ្ទៃក្នុងឡើយ ករណីជាមានសំណើសុំដោះលែងថ្មីមួយ ត្រូវបានធ្វើឡើងបន្ទាប់មកទៀតនៅចំពោះមុខអង្គជំនុំជម្រះ"[11]។

---

[6] ឯកសារលេខ **D427/4/14** សេចក្តីសម្រេចលើបណ្តឹងសាទុក្ខរបស់ ខៀវ សំផន ប្រឆាំងនឹងដីកាដំណោះស្រាយ , ចុះថ្ងៃទី១៣ មករា ២០១១។*សូមអានផងដែរ*ឯកសារលេខ **D427/4/15** សេចក្តីសម្រេចលើបណ្តឹងសាទុក្ខរបស់ ខៀវ សំផន ប្រឆាំងនឹងដីកាដំណោះស្រាយ , ចុះថ្ងៃទី២១ មករា ២០១១។.

[7] ឯកសារលេខ **D427/4/15** សេចក្តីសម្រេចលើបណ្តឹងសាទុក្ខរបស់ ខៀវ សំផន ប្រឆាំងនឹងដីកាដំណោះស្រាយ , ចុះថ្ងៃទី២១ មករា ២០១១។

[8] ឯកសារលេខ **E18** ពាក្យសុំដោះលែងឲ្យនៅក្រៅឃុំអនុលោមតាមវិធាន៨២(៣) នៃវិធានផ្ទៃក្នុង, ចុះថ្ងៃទី១៨មករា ២០១១។

[9] ឯកសារលេខ **E1/1.1** T. ចុះថ្ងៃទី៣១ មករា ២០១១។

[10] ឯកសារលេខ **E50** សេចក្តីសម្រេចលើសំណើសុំដោះលែងជាបន្ទាន់របស់ នួនជា, ខៀវ សំផន, និង អៀង ធីរិទ្ធ, ចុះថ្ងៃទី១៦ កុម្ភៈ ២០១១។

[11] ឯកសារលេខ **E50** សេចក្តីសម្រេចលើសំណើសុំដោះលែងជាបន្ទាន់របស់ នួន ជា, ខៀវ សំផន, និង អៀង ធីរិទ្ធ, ចុះថ្ងៃទី១៦ កុម្ភៈ ២០១១ , ត្រង់កថាខណ្ឌទី៤២។

៧- កាលពីថ្ងៃទី៣ ខែមីនា ឆ្នាំ២០១១ មេធាវីការពារក្តីបានប្តឹងសាទុក្ខប្រឆាំងនឹងសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងចុះថ្ងៃទី១៦ ខែកុម្ភៈ ឆ្នាំ២០១១[12]។ សហព្រះរាជអាជ្ញាបានឆ្លើយតប កាលពីថ្ងៃទី២៨ ខែមីនា ឆ្នាំ២០១១[13] ហើយជនជាប់ចោទបានធ្វើសារណាតបកាលពីថ្ងៃទី១១ ខែមេសា ឆ្នាំ២០១១[14]។ នៅក្នុងសេចក្តីសម្រេច កាលពីថ្ងៃទី៦ ខែមិថុនា ឆ្នាំ២០១១ របស់ខ្លួន ដែលបដិសេធចោលនូវបណ្តឹងសាទុក្ខរបស់មេធាវីការពារក្តី អង្គជំនុំជម្រះតុលាការកំពូលបានសម្រេចនៅត្រង់ផ្នែកដែលពាក់ព័ន្ធថា៖ ការឃុំខ្លួនជនជាប់ចោទមានសុពលភាពអនុលោមតាមវិធាន៦៣(៣)(ខ)(iii) នៃវិធានផ្ទៃក្នុង ដោយផ្អែកលើមូលដ្ឋានថា មានហានិភ័យអំពីការមិនមានវត្តមានរបស់ជនជាប់ចោទ នៅក្នុងពេលសវនាការ។ អង្គជំនុំជម្រះសាលាដំបូងមិនមានកំហុស ក្នុងការមិនបានពិនិត្យពិចារណាឲ្យបានច្បាស់លាស់ក្នុងការដោះលែងឲ្យនៅក្រៅឃុំ ដោយដាក់ឲ្យស្ថិតនៅក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការនោះឡើយ ព្រោះមេធាវីការពារក្តីមិនបានចង្អុលបង្ហាញភ័ស្តុតាងអំពី "កាលៈទេសៈនានាដែលទាក់ទងនឹងអង្គហេតុ និងអំពីលក្ខខណ្ឌដែលផ្សាភ្ជាប់ទៅនឹងការដាក់ឲ្យស្ថិតនៅក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការនោះ" ហើយដំណោះស្រាយតាមផ្លូវច្បាប់របស់អង្គជំនុំជម្រះ មិនបានតម្រូវឲ្យមានការផ្លាស់ប្តូរកាលៈទេសៈនៅក្នុងសំណើសុំជាបន្ទាប់មកទៀត គឺជាដំណោះស្រាយតាមផ្លូវច្បាប់គ្រប់គ្រាន់សម្រាប់វិការៈនីតិវិធីណាមួយក្នុងអង្គជំនុំជម្រះសាលាដំបូង មិនបានផ្តល់នូវសេចក្តីជូនដំណឹងជាមុនថា កត្តាទាំងឡាយដែលនៅក្នុងវិធាន៦៣(៣)នៃវិធានផ្ទៃក្នុង គួរតែត្រូវបានយកមកពិភាក្សានៅក្នុងសវនាការដោយផ្ទាល់មាត់[15]។

៨- កាលពីថ្ងៃទី២៩ ខែមីនា ឆ្នាំ២០១៣ មេធាវីការពារក្តីបានដាក់សំណើមួយថ្មីសុំឲ្យដោះលែងជនជាប់ចោទឲ្យនៅក្រៅឃុំជាបន្ទាន់[16]។ មេធាវីការពារក្តីបានទាមទារថា៖ លែងមានយុត្តិកម្មណាមួយតទៅទៀតសម្រាប់ការឃុំខ្លួនជនជាប់ចោទតទៅទៀតហើយ ការបន្តការឃុំខ្លួនតទៅទៀតនោះ បានរំលោភ

---

[12] ឯកសារលេខ **E50/3** បណ្តឹងសាទុក្ខប្រឆាំងនឹងសេចក្តីសម្រេចលើសំណើសុំដោះលែង ខៀវ សំផន ឲ្យនៅក្រៅឃុំជាបន្ទាន់, ចុះថ្ងៃទី៣ មីនា ២០១១។

[13] ឯកសារលេខ **E50/3/1/1**, ចម្លើយតបរបស់សហព្រះរាជអាជ្ញា ទៅនឹងបណ្តឹងសាទុក្ខរបស់ ខៀវ សំផន ប្រឆាំងនឹងសេចក្តីសម្រេចលើសំណើសុំដោះលែងឲ្យនៅក្រៅឃុំយជាបន្ទាន់, ចុះថ្ងៃទី២៨ មីនា ២០១១។

[14] ឯកសារលេខ **E50/3/1/3** សារណាតប, ចុះថ្ងៃទី១១ មេសា ២០១១។

[15] ឯកសារលេខ **E50/3/1/4** សេចក្តីសម្រេចលើបណ្តឹងសាទុក្ខភ្លាមៗរបស់ ខៀវ សំផន ស្តីពីសំណើសុំដោះលែងឲ្យនៅក្រៅឃុំ, ចុះថ្ងៃទី៦ មិថុនា ២០១១, កថាខណ្ឌទី៥៤,៥៥ និង៥៨។

[16] ឯកសារលេខ **E275** សំណើសុំដោះលែង ខៀវ សំផន ឲ្យនៅក្រៅឃុំជាបន្ទាន់ ដោយដាក់ឲ្យស្ថិតនៅក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការ , ចុះថ្ងៃទី២៩ មីនា ២០១៣។

ទៅលើសិទ្ធិរបស់ជនជាប់ចោទ ដោយហេតុថា “មិនមានសាលក្រមក្នុងពេលអនាគតដែលអាចព្យាករបាន និងក្នុងអនាគតមិនឆ្ងាយពេកទេ” និងដោយសារតែវ័យជរារបស់ជនជាប់ចោទនោះឡើយ ហើយថាការដោះលែងតាមការដាក់ឲ្យស្ថិតនៅក្រោមការត្រួតពិនិត្យតាមតុលាការដែលស្នើសុំឲ្យផ្តល់នោះ គឺគ្រប់គ្រាន់សម្រាប់ដោះស្រាយចំពោះហានិភ័យណាមួយនោះេឡើយ[17]។ នៅក្នុងខណៈដែលសហព្រះរាជអាជ្ញាមិនត្រូវបានអនុញ្ញាតឲ្យដាក់ចម្លើយតបជាលាយលក្ខណ៍អក្សរ នៅក្នុងពេលសវនាការលើសំណើសុំនេះ សហព្រះរាជអាជ្ញាបានឆ្លើយតបថា៖ លក្ខខណ្ឌតាមវិធាន៦៣(៣)(ខ)នៃវិធានផ្ទៃក្នុងនៅបន្តមានអត្ថិភាពធ្វើយុត្តិកម្មចំពោះការឃុំខ្លួនតទៅទៀត[18] ដោយបានកត់សម្គាល់ថាមេធាវីការពារក្តីបានបកស្រាយខុសនូវប្រភពច្បាប់យោងរបស់ខ្លួន នៅក្នុងការទាមទារអំពីកង្វះភាពប្រាកដប្រជាផ្នែកច្បាប់[19]។ករណីរឿងក្តីនៅឯតុលាការ ECHR ដែលមេធាវីការពារក្តីបានពឹងផ្អែកនោះ គឺមានការជាប់ទាក់ទងដោយមានកម្រិត[20]។ ហើយថា ការចោទប្រកាន់ផ្សេងៗរបស់មេធាវីការពារក្តីដែលថាគ្មានភាពប្រាកដប្រជា និងការអូសបន្លាយដំណើរការនីតិវិធីនោះ គឺមិនដកចេញនូវការពិនិត្យពិច័យយ៉ាងហ្មត់ចត់នេះបានទេ[21]។

៩- កាលពីថ្ងៃទី២៦ ខែមេសា ឆ្នាំ២០១៣ អង្គជំនុំជម្រះសាលដំបូងបានចេញសេចក្តីសម្រេចមួយដែលរងការជំទាស់ដែលបានច្រានចោលនូវសំណើរបស់មេធាវីការពារក្តី និងបានចេញសេចក្តីសម្រេចឲ្យបន្តការឃុំខ្លួនជនជាប់ចោទដោយអនុលោមតាមវិធាន៦៣(៣)(ខ)(iii)នៃវិធានផ្ទៃក្នុង ដោយផ្អែកលើមូលដ្ឋាននៃភាពចាំបាច់ ក្នុងការធានាឲ្យមានវត្តមានជនជាប់ចោទ នៅក្នុងពេលដំណើរការនីតិវិធីនៃការជំនុំជម្រះក្តី[22]។ អង្គជំនុំជម្រះសាលាដំបូងបានសម្រេចថា ដោយសារដំណាក់កាលឈានទៅមុខ និងភាពស្មុគ្រស្មាញនៃសវនាការ ការមិនចូលមកបង្ហាញខ្លួនរបស់ជនជាប់ចោទ ដោយចេតនា ឬមិនដោយចេតនា គឺមុខជានឹងធ្វើឲ្យមានហានិភ័យអំពីការអូសបន្លាយដល់ការបញ្ចប់សវនាការឲ្យបានយ៉ាងឆាប់រហ័ស។ អង្គជំនុំជម្រះសាលាដំបូងក៏មានការព្រួយបារម្ភផងដែរថាហានិភ័យអំពីការរត់គេចខ្លួនរបស់

[17] ឯកសារលេខ **E275** សំណើសុំដោះលែង ខៀវ សំផន ឲ្យនៅក្រៅឃុំជាបន្ទាន់ ដោយដាក់ឲ្យស្ថិតនៅក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការ , ចុះថ្ងៃទី២៩ មីនា ២០១៣ ឯកសារលេខ **E1/180.1** T. ចុះថ្ងៃទី១១ មេសា ២០១៣។

[18] ឯកសារលេខ **E1/180.1** T. ចុះថ្ងៃទី១១ មេសា ២០១៣, ទំព័រ៩៨ និង ពីទី១០៦-១១៧។

[19] ឯកសារលេខ **E1/180.1** T. ចុះថ្ងៃទី១១ មេសា ២០១៣, ទំព័រ៩៩។

[20] ឯកសារលេខ **E1/180.1** T. ចុះថ្ងៃទី១១ មេសា ២០១៣, ទំព័រទី១០០-១០១។

[21] ឯកសារលេខ**E1/180.1** T. ចុះថ្ងៃទី១១ មេសា ២០១៣, ទំព័រទី១០២-១០៦។

[22] ឯកសារលេខ **E275/1** សេចក្តីសម្រេចដែលរងការជំទាស់ ត្រង់កថាខណ្ឌទី២៣។

ជនជាប់ចោទបានកើនឡើងមកទល់ត្រឹមដំណាក់កាលចុងក្រោយនៃការជំនុំជម្រះក្តី។ អង្គជំនុំជម្រះសាលាដំបូងបានសម្រេចថា ការធានារ៉ាប់រងជាមុនដែលផ្តល់ដោយជនជាប់ចោទ និងក្រុមគ្រួសាររបស់គាត់[23] គឺមិនគ្រប់គ្រាន់សម្រាប់ឲ្យធ្វើការថ្លឹងថ្លែងទេ។ អង្គជំនុំជម្រះបានច្រានចោលនូវការជំទាស់របស់មេធាវីការពារក្តីដែលថា សាលក្រមមិនអាចព្យាករទុកជាមុនបាន ហើយបានរកឃើញថា រយៈពេលយូរនៃការឃុំខ្លួនបណ្តោះអាសន្នរបស់ជនជាប់ចោទត្រូវបានធ្វើយុត្តិកម្មនៅក្នុងកាលៈទេសៈជារួមទាំងអស់[24]។

១០- នៅក្នុងបណ្តឹងសាទុក្ខ មេធាវីការពារក្តីបានអះអាងថា អង្គជំនុំជម្រះសាលាដំបូងបានមានកំហុស៖ ដោយខកខានមិនបានផ្តល់នូវមូលហេតុគ្រប់គ្រាន់សម្រាប់ការធ្វើសេចក្តីសម្រេចរបស់ខ្លួន ដោយកត្តានានាដែលខ្លួនបានយកមកពិនិត្យពិចារណាក្នុងការចេញដីកាសម្រេចឲ្យបន្តការឃុំខ្លួន និងស្ថានទម្ងន់ដែលខ្លួនបានផ្តល់ ដោយការគណនាមិនបានត្រឹមត្រូវអំពីរយៈពេលយូរនៃការឃុំខ្លួនបណ្តោះអាសន្ន និងដោយការប្រកែកមិនទទួលយកនូវភ័ស្តុតាងដែលបានបង្ហាញអំពីការអូសបន្លាយពេល នៅក្នុងដំណាក់កាលស៊ើបសួរ ដោយការរកឃើញថាមិនមានកង្វះខាតគ្រប់គ្រាន់អំពីការអាចព្យាករណ៍បាន និងភាពប្រាកដប្រជាទាក់ទងទៅនឹងការចេញសាលក្រមនោះឡើយ និងដោយការពឹងផ្អែកទៅលើវិធាន៨២(៤) នៃវិធានផ្ទៃក្នុង ក្នុងការច្រានចោលនូវសំណើថ្មីរបស់ជនជាប់ចោទដែលសុំឲ្យដោះលែងឲ្យនៅក្រៅឃុំជាបន្ទាន់។ លើសពីនេះ មេធាវីការពារក្តីបានចោទប្រកាន់ថែមទៀថា រួមទាំង កាលៈទេសៈនៃការអូសបន្លាយ និងទាំងភាពមិនអាចទាយទុកជាមុនបានរបស់តុលាការ និងភាពមិនប្រាកដប្រជា ក៏ដូចជាវ័យជរារបស់ជនជាប់ចោទ បានធ្វើឲ្យរយៈពេលនៃការឃុំខ្លួនបណ្តោះអាសន្នរបស់ជនជាប់ចោទ វែងលើសពីការកំណត់[25]។

## III. **ភាពអាចទទួលយកបាន**

១១- អង្គជំនុំជម្រះតុលាការកំពូលមានយុត្តាធិការលើបណ្តឹងសាទុក្ខ អនុលោមតាមវិធាន១០៤(៤)(ខ)នៃវិធានផ្ទៃក្នុង ដែលអនុញ្ញាតឲ្យប្តឹងសាទុក្ខចំពោះ "សេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងស្តីពីការឃុំខ្លួន និងការដាក់ឲ្យស្ថិតនៅក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការតាមវិធាន៨២"[26]។មេធាវីការ

[23] ឯកសារលេខ **E275/1** សេចក្តីសម្រេចដែលរងការជំទាស់ ត្រង់កថាខណ្ឌទី២១។

[24] ឯកសារលេខ **E275/1** សេចក្តីសម្រេចដែលរងការជំទាស់ ត្រង់កថាខណ្ឌទី២៣។

[25] ឯកសារលេខ **E275/2/1** បណ្តឹងសាទុក្ខរបស់ ខៀវ សំផន។

[26] វិធាន៨២ នៃវិធានផ្ទៃក្នុង។ ឯកសារលេខ **E50/3/1/4** សេចក្តីសម្រេចលើបណ្តឹងសាទុក្ខភ្លាមៗ ត្រង់កថាខណ្ឌទី២១។

ពារក្តីបានធ្វើការចោទប្រកាន់ថាអង្គជំនុំជម្រះសាលាដំបូងបានមានកំហុស ទាំងខាងអង្គហេតុ និងខាងអង្គច្បាប់ និង/ឬ ខាងឆន្ទានុសិទ្ធិអនុលោមតាមវិធាន១០៥(២)។

## IV. ភាពទាន់ពេលវេលា

១២- សហព្រះរាជអាជ្ញាសន្និដ្ឋានថា បណ្តឹងសាទុក្ខដែលធ្វើមិនទាន់ពេលវេលា ដោយសារបណ្តឹងនេះមិនត្រូវបានធ្វើនៅក្នុងរយៈពេលដែលបានកំណត់ជាធរមាន ដែលហេតុដូចនេះ គួរតែត្រូវបានបដិសេធ។ សេចក្តីសម្រេចដែលរងការជំទាស់ត្រូវបានជូនដំណឹងទៅដល់ភាគីនានា កាលពីថ្ងៃទី២៦ ខែមេសា ឆ្នាំ២០១៣។ អនុលោមតាមវិធាន១០៧(២)នៃវិធានផ្ទៃក្នុង មេធាវីការពារក្តីបានមានពេលរហូតទៅដល់ថ្ងៃទី១៦ ខែឧសភា ឆ្នាំ២០១៣ ដើម្បីដាក់បណ្តឹងសាទុក្ខរបស់ខ្លួន[27]។ អនុលោមតាមសេចក្តីណែនាំអនុវត្តមាត្រា៧.១ ឯកសារទាំងឡាយត្រូវតែដាក់ជាភាសាខ្មែរ ឬមួយជាភាសាបារាំង ឬអង់គ្លេស។ នៅក្នុងពេលដែលអត្ថបទជាភាសាបារាំងត្រូវបានដាក់កាលពីថ្ងៃទី១៦ ខែឧសភា ឆ្នាំ២០១៣នោះ នៅពេលបណ្តឹងសាទុក្ខជាភាសាបារាំងបានដាក់នៅថ្ងៃទី១៦ ខែឧសភា ឆ្នាំ២០១៣ អត្ថបទជាភាសាខ្មែរមិនទាន់បានដាក់នៅឡើយទេ រហូតទាល់តែដល់ថ្ងៃទី២២ ខែឧសភា ឆ្នាំ២០១៣ គឺប្រាំថ្ងៃហួសកាលបរិច្ឆេទកំណត់។ សហព្រះរាជអាជ្ញាមិនបានដឹងអំពីសំណើណាមួយពីមេធាវីការពារក្តី ដែលសុំការអនុញ្ញាតដើម្បីដាក់តែមួយភាសាប៉ុណ្ណោះអនុលោមតាមសេចក្តីណែនាំអនុវត្តមាត្រា៧.២ ឬដើម្បីសុំឲ្យចាត់ទុកថា បណ្តឹងសាទុក្ខត្រូវបានដាក់ទាន់ពេលវេលាដោយគិតត្រឡប់ទៅក្រោយវិញ អនុលោមតាមវិធាន៣៩(៤)(ខ)នោះឡើយ។

១៣- អនុលោមតាមវិធាន៣៩(១)នៃវិធានផ្ទៃក្នុង ការខកខានរបស់ភាគីណាមួយក្នុងការមិនបានគោរពតាមកាលបរិច្ឆេទកំណត់ជាធរមាន "នឹងនាំឲ្យអសុពលភាពដល់បណ្តឹងនោះ"។ សហព្រះរាជអាជ្ញាសន្និដ្ឋានថា នៅក្នុងករណីចំពោះមុខ បើសិនជាបណ្តឹងសាទុក្ខមិនបានដាក់ទាន់ពេលវេលា ឬបើសិនជាមេធាវីការពារក្តីមិនបានស្នើសុំនូវវិធានការពិសេស ឬមិនបានជូនដំណឹងឲ្យអង្គជំនុំជម្រះ ឬភាគីផ្សេងទៀតបានជ្រាបអំពីការពន្យារពេលរបស់ខ្លួន ឬព្រមជាមួយនឹងការបញ្ជាក់ពីមូលហេតុឲ្យបានត្រឹមត្រូវទេនោះ បណ្តឹងសាទុក្ខនេះគួរតែត្រូវបានចាត់ទុកថាមិនទាន់ពេលវេលា ហើយអាស្រ័យហេតុនេះ គួរតែ

[27] នេះគឺរាប់បញ្ចូលទាំងថ្ងៃឈប់សម្រាកបុណ្យនៅថ្ងៃទី១៣,១៤, និង១៥ ខែមិថុនា ឆ្នាំ២០១៣ផង។

ត្រូវបានបដិសេធចោល។ បន្ថែមពីលើនេះ ត្រូវលើកមូលហេតុថា *សំណើក្រោយពីនេះ* អាចនឹងដាក់ពីមេធាវីការពារក្តីដោយសារការពន្យារពេលពិសេសនាពេលនេះ ដែលកំហុសរបស់ពួកគេត្រូវបានកត់សម្គាល់ គឺមិនគួរត្រូវបានលើកទឹកចិត្តខ្លាំងពេកទេ ព្រោះនោះមុខជានឹងជួយជម្រុញលើទឹកចិត្តដល់ការដាក់ឯកសារយឺតចុងក្រោយឱ្យទៅជា*ការដាក់ស្ទាត់ៗ*។

១៤- ចម្លើយតបនេះគឺធ្វទាន់ពេលវេលា ដោយត្រូវបានដាក់នៅក្នុងអម្លុងពេល១០ថ្ងៃចាប់តាំងពីពេលសហព្រះរាជអាជ្ញាកំពុងត្រូវបានជូនដំណឹងអំពីបណ្តឹងសាទុក្ខរបស់មេធាវីការពារក្តីដែលបានធ្វើឱ្យសុក្រិតឡើង កាលពីថ្ងៃទី២៧ ខែឧសភា ឆ្នាំ២០១៣[28]។

## V. ច្បាប់ជាធរមាន

### ក. វិសាលភាពនៃការពិនិត្យឡើងវិញលើបណ្តឹងសាទុក្ខ និងយុត្តាធិការត្រឹមត្រូវ

#### *i. ការពិនិត្យឡើងវិញលើបណ្តឹងសាទុក្ខ*

១៥- វិធាន១០៤នៃវិធានផ្ទៃក្នុងចែងថា អង្គជំនុំជម្រះតុលាការកំពូលត្រូវសម្រេចលើបណ្តឹងសាទុក្ខ ដោយផ្អែកលើមូលដ្ឋាននៃមូលហេតុមួយ ឬច្រើនក្នុងចំណោមមូលហេតុដូចខាងក្រោមនេះ៖ កំហុសលើអង្គច្បាប់ដែលនាំឱ្យមោឃៈដល់សេចក្តីសម្រេច។ កំហុសលើអង្គច្បាប់ ដែលនាំឱ្យមានភាពមិនយុត្តិធម៌ ឬកំហុសជាក់ស្តែងចេញពីការប្រើឆន្ទានុសិទ្ធិរបស់អង្គជំនុំជម្រះសាលាដំបូង ដែលនាំឱ្យប៉ះពាល់ដល់សិទ្ធិរបស់ម្ចាស់បណ្តឹងសាទុក្ខ។ មូលហេតុទាំងនេះ មានភាពខុសៗពីគ្នា[29]។ ហេតុដូចនេះចំពោះកំហុសណាមួយ ការខូចខាត ឬការធ្វើឱ្យប៉ះពាល់ ត្រូវតែធ្លាក់ទៅលើម្ចាស់បណ្តឹងសាទុក្ខ ដើម្បីធានាឱ្យមានដំណោះស្រាយចំពោះមូលដ្ឋាននៃបណ្តឹងសាទុក្ខ។

១៦- វិសាលភាពនៃការពិនិត្យឡើងវិញលើបណ្តឹងសាទុក្ខរបស់អង្គជំនុំជម្រះតុលាការកំពូល អំពីសេចក្តីសម្រេចដែលរងការជំទាស់ ត្រូវបានកម្រិតត្រឹមមូលហេតុដែលបានលើកឡើងនៅក្នុងបណ្តឹងសាទុក្ខ

[28] សេចក្តីណែនាំអនុវត្ត អវតក/០១/២០០៧/វិ.៨, ស្តីពីការដាក់ឯកសារនៅចំពោះមុខ អវតក, មាត្រា ៨.៣។

[29] ឯកសារលេខ**E50/3/1/4** សេចក្តីសម្រេចលើបណ្តឹងសាទុក្ខភ្លាមៗ, ត្រង់កថាខណ្ឌទី២០។

តែប៉ុណ្ណោះ[30]។ ក៏ប៉ុន្តែចំពោះបញ្ហាទាំងឡាយដែលស្ថិតនៅក្នុងវិសាលភាពនៃបណ្តឹងសាទុក្ខវិញ អង្គជំនុំជម្រះតុលាការកំពូល អាចពិចារណាជាថ្មីឡើងវិញលើមូលដ្ឋានសម្រាប់គាំទ្រអង្គហេតុនៃសេចក្តីសម្រេចដែលរងការជំទាស់ និងជំនួសសម្អាងហេតុចំពោះការយល់ឃើញ នៅក្នុងសេចក្តីសម្រេចដំបូង។[31]។

### *ii. យុត្តាធិការត្រឹមត្រូវ*

១៧- លើសពីនេះ "បន្ទុកត្រូវឋិតនៅលើភាគីដែលជំទាស់នឹងសេចក្តីសម្រេចដោះលែងបណ្តោះអាសន្ន ដែលត្រូវបង្ហាញថាអង្គជំនុំជម្រះសាលាដំបូងមាន "កំហុសជាក់ស្តែងបាន"[32]។

## ខ. ការវាយតម្លៃលើការឃុំខ្លួនបណ្តោះអាសន្ន

### *i. តេស្តដែលមានពីរដំណាក់កាល*

១៨- ដោយហេតុថាលក្ខខណ្ឌនានាដែលមានមុនចំពោះដីកាបង្គាប់ឲ្យឃុំខ្លួនបណ្តោះអាសន្ន វិធាន ៦៣(៣) នៃវិធានផ្ទៃក្នុង តម្រូវឲ្យមាន ទីមួយ "មូលហេតុដែលត្រូវបានរកឃើញ និងជឿជាក់យ៉ាងច្បាស់ថាជនដែលនឹងត្រូវឃុំខ្លួន បានប្រព្រឹត្តបទល្មើសដូចដែលត្រូវបានចោទប្រកាន់"[33] ដូច្នេះមែន យ៉ាងហោចណាស់ក៏ត្រូវមានទទ្បីករណ៍មួយក្នុងចំណោមទទ្បីករណ៍ទាំងប្រាំ ដែលបានរៀបរាប់នៅក្នុងវិធាន ៦៣(៣)(ខ)នៃវិធានផ្ទៃក្នុងដែរ[34]។ ទាក់ទងទៅនឹងបណ្តឹងសាទុក្ខ ទទ្បីករណ៍ដែលអនុញ្ញាតឲ្យមានការឃុំខ្លួន ត្រូវបានរកឃើញដោយអង្គជំនុំជម្រះសាលាដំបូង ដើម្បី "ធានាអំពីវត្តមានរបស់ជនត្រូវចោទនៅក្នុងដំណើរការនីតិវិធី"[35]។

---

[30] ឯកសារលេខ**E50/3/1/4** សេចក្តីសម្រេចលើបណ្តឹងសាទុក្ខភ្លាមៗ, ត្រង់កថាខណ្ឌទី៥២។

[31]ឯកសារលេខ **E50/3/1/4** សេចក្តីសម្រេចលើបណ្តឹងសាទុក្ខភ្លាមៗ, ត្រង់កថាខណ្ឌទី៥២។ អនុវិធាន១០៤(១) ផ្តល់ជូនអង្គជំនុំជម្រះតុលាការកំពូលនូវឆន្ទានុសិទ្ធិក្នុងការ "ពិនិត្យភស្តុតាង និង ស្នើឲ្យផ្តល់ភស្តុតាងថ្មី," រីឯអនុវិធាន១០៤(២)វិញ ផ្តល់សិទ្ធិអំណាចដល់អង្គជំនុំជម្រះតុលាការកំពូលក្នុងការកែប្រែលើសេចក្តីសម្រេចដែលកំពុងតែត្រូវបានប្តឹងសាទុក្ខ លើផ្នែកខ្លះ ឬទាំងមូល។

[32] **រដ្ឋអាជ្ញា ទល់នឹង Zdravko Tolimir និងគូកន,** សេចក្តីសម្រេចលើបណ្តឹងសាទុក្ខបន្ទាន់បង្ខំជំទាស់នឹងសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូង ដែលអនុញ្ញាតឲ្យមានការដោះលែងបណ្តោះអាសន្ន, ១៩ តុលា ២០០៥, កថាខណ្ឌ ៤។

[33] **E50/3/1/4** សេចក្តីសម្រេចលើបណ្តឹងសាទុក្ខភ្លាមៗ, ត្រង់កថាខណ្ឌ ៣៩។

[34] **E50/3/1/4** សេចក្តីសម្រេចលើបណ្តឹងសាទុក្ខភ្លាមៗ, ត្រង់កថាខណ្ឌ ៣៩។

[35] វិធាន ៦៣(៣)(ខ) នៃវិធានផ្ទៃក្នុង។ **E275/1** សេចក្តីសម្រេចដែលរងការជំទាស់ ត្រង់កថាខណ្ឌ ២១។

១៩- អង្គជំនុំជម្រះនេះបានសម្រេចថា នៅក្នុងការវាយតម្លៃថាតើការឃុំខ្លួនបណ្តោះអាសន្ន គឺជាវិធានការចាំបាច់ ដើម្បីធានាអំពីវត្តមានរបស់ជនជាប់ចោទ៖

> គឺសមហេតុសមផលមួយហើយដែលអង្គជំនុំជម្រះសាលាដំបូង ត្រូវធ្វើការពិចារណាអំពីភាពធ្ងន់ធ្ងរនៃឧក្រិដ្ឋកម្មដែលចោទប្រកាន់ ដើម្បីកំណត់ថាតើបញ្ហាប្រឈមចំពោះលទ្ធភាពនៃការដាក់ទោសធ្ងន់ធ្ងរ អាចបង្កើតចេតនាក្នុងការរត់គេចខ្លួនរបស់ជនជាប់ចោទ។ មានភ័ស្តុតាងបង្ហាញថា នៅពេលដែលជនជាប់ចោទប្រឈមមុខនឹងការដាក់ ទោសកាន់តែធ្ងន់នោះ ចេតនាក្នុងការរត់គេចខ្លួនកាន់តែមានខ្លាំងឡើងដែរ[36]។

២០- យ៉ាងណាក៏ដោយ អង្គជំនុំជម្រះនេះបានកត់សម្គាល់ថា ភាពធ្ងន់ធ្ងរនៃឧក្រិដ្ឋកម្មដែលបានចោទប្រកាន់ គឺជាកត្តាតែមួយគត់ដែលគេត្រូវធ្វើការពិចារណា ហើយថាការរំពឹងទុកថានឹងមានការដាក់ទោសយូរនោះ មិនអាចជា “កត្តាតែមួយគត់ក្នុងការកំណត់ពីលទ្ធផលនៃពាក្យស្នើសុំដោះលែង” នោះឡើយ[37]។

២១- វិសាលភាពនៃការពិចារណាដែលទាក់ទិននឹងការធានាអំពីវត្តមានរបស់ជនជាប់ចោទ គឺមានភាពទូលំទូលាយជាងការគ្រាន់តែមានហានិភ័យដែលថាជនជាប់ចោទនោះនឹងរត់គេចខ្លួនទៅទៀត។ គឺវាគ្របដណ្តប់ទៅលើការពិចារណាដទៃទៀត ដែលអាចនឹងបណ្តាលឲ្យជនជាប់ចោទមិនមានលទ្ធភាពមកធ្វើសវនាការបាន ដូចជាហានិភ័យនានាដែលជនជាប់ចោទអាចនឹងទៅលាក់ខ្លួន, មិនគោរពតាមដីកាកោះ ឬក៏អាចនឹងត្រូវបានរារាំងជាបណ្តោះអាសន្ន និងដោយអចេតនា មិនឲ្យចូលរួមក្នុងសវនាការបាន ដូចជា ដោយសារមានចលាចលសាធារណៈ ឬមានការវាយប្រហារទៅលើរូបគាត់ជាបុគ្គលជាដើម[38]។ ហានិភ័យនៃដំណើរការដ៏ឆាប់រហ័សនៃកិច្ចដំណើរការនីតិវិធី ដែលត្រូវបានប្រឈមនឹងលទ្ធភាពទាំងអស់នេះ បានធ្វើឲ្យវាក្លាយទៅជាការពិចារណាដែលប្រកបទៅដោយសុពលភាពនៅក្នុងការកំណត់ថាតើការបន្តការឃុំខ្លួនមានយុត្តិកម្មហើយឬនៅ។ ដូចដែលអង្គជំនុំជម្រះតុលាការកំពូលបានកត់សម្គាល់នៅក្នុងសេចក្តីសម្រេចរបស់ខ្លួន កាលពីខែមិថុនា ឆ្នាំ២០១១ ដូច្នោះដែរថា “សូម្បីតែ ករណីតែមួយគត់

---

[36] **E50/3/1/4** សេចក្តីសម្រេចលើបណ្តឹងសាទុក្ខភ្លាមៗ, កថាខណ្ឌ ៤០, ដោយបានលើកឡើងពីសំណុំរឿងលេខ IT-03-73-AR65.1, *រដ្ឋអាជ្ញា ទល់នឹង Ivan Cermak និង Mladen Markac,* សេចក្តីសម្រេចលើបណ្តឹងសាទុក្ខបន្ទាន់បង្អំជំទាស់នឹងសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូង ដែលបដិសេធលើការដោះលែងបណ្តោះអាសន្ន, ២ ធ្នូ ២០០៤, កថាខណ្ឌ ២៥។

[37] **E50/3/1/4** សេចក្តីសម្រេចលើបណ្តឹងសាទុក្ខភ្លាមៗ, ត្រង់កថាខណ្ឌ ៤០។

[38] **E50/3/1/4** សេចក្តីសម្រេចលើបណ្តឹងសាទុក្ខភ្លាមៗ, ត្រង់កថាខណ្ឌ ៥៤។

ដែលជនជាប់ចោទខកខានមិនអាចបង្ហាញខ្លួននៅចំពោះមុខតុលាការ អាចនឹងធ្វើឲ្យមហន្តរាយដល់លទ្ធភាពនៃការចេញសាលក្រម ក្នុងរយៈពេលវេលាសមស្រប" ហើយធ្វើឲ្យមាការរាំងស្ទះដល់គោលបំណងនៃកិច្ចដំណើរការនីតិវិធីដ៏ឆាប់រហ័សនោះ[39]។

២២- លើសពីនេះ "អង្គជំនុំជម្រះសាលាដំបូងមានឆន្ទានុសិទ្ធិដ៏ច្រើនសន្ធឹកនៅពេលធ្វើការកំណត់ថាតើ កត្តាអ្វីខ្លះ ដែលនឹងមានការពាក់ព័ន្ធទៅនឹងការវាយតម្លៃរបស់ខ្លួនអំពីថាតើវាត្រូវទៅនឹងលក្ខខណ្ឌ តម្រូវនៃការឃុំខ្លួនបណ្តោះអាសន្ន]មួយណា ហើយ... អង្គជំនុំជម្រះសាលាដំបូងក៏មានឆន្ទានុសិទ្ធិដ៏ច្រើនសន្ធឹកផងដែរ នៅពេលធ្វើការកំណត់អំពីទម្ងន់ដើម្បីអនុញ្ញាតឲ្យមានកត្តាទាំងនេះឡើង ដោយគិតដល់កាលៈទេសៈជាក់លាក់នានានៃរឿងក្តីនីមួយៗ"[40]។

*ii. ការសន្មតទុកជាមុននូវទឡ្ហីករណ៍ដែលត្រូវបន្តការឃុំខ្លួន និងការអនុវត្តនាទាសម្រាប់ការដោះលែង*

២៣- ដោយអនុលោមតាមវិធាន ៨២(១) នៃវិធានផ្ទៃក្នុង កាលណាជនជាប់ចោទ "ត្រូវបានឃុំខ្លួននៅពេលចូលខ្លួនលើកដំបូង នៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង ជនជាប់ចោទត្រូវស្ថិតនៅក្នុងឃុំដែលរហូតដល់ពេលសាលក្រមនៃអង្គជំនុំជម្រះសាលាដំបូង ត្រូវបានសម្រេចសេចក្តី" លើកលែងតែ គេបានចេញដីកាបង្គាប់ឲ្យដោះលែង ទៅតាមវិធាន ៨២(២) នៃវិធានផ្ទៃក្នុង។ បទប្បញ្ញត្តិនេះ បានបង្កើតនូវការសន្មតទុកជាមុនមួយតាមអង្គហេតុដែលអាចជំទាស់បានថា ទឡ្ហីករណ៍ទាំងឡាយ ដែលសហចៅក្រមស៊ើបអង្កេតចាត់ទុកថា បានធ្វើយុត្តិកម្មដល់ការឃុំខ្លួនបណ្តោះអាសន្ន គឺនៅដដែលរហូតដល់គេបានចេញសាលក្រម[41]។ ដូច្នេះ "ចាប់ពីពេលបង្ហាញខ្លួនលើកដំបូង រហូតដល់ពេលការចេញសាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង គឺជាបន្ទុករបស់ជនជាប់ចោទ ក្នុងការតវ៉ាប្រឆាំងទៅនឹងមូលដ្ឋាននៃការឃុំខ្លួនតាមការស្នើសុំទៅអង្គជំនុំជម្រះសាលាដំបូង"[42]។ លើសពីនេះ បន្ទុកក្នុងការចង្អុលភ័ស្តុតាងលើលក្ខខណ្ឌ និងកាលៈទេសៈនានា តាមអង្គហេតុក្នុងការធ្វើឲ្យការដាក់ឲ្យស្ថិតនៅ

[39] **E50/3/1/4** សេចក្តីសម្រេចលើបណ្តឹងសាទុក្ខភ្លាមៗ, ត្រង់កថាខណ្ឌ ៥៤។

[40] *រដ្ឋអាជ្ញា ទល់នឹង Vujadin Popović និងគូកន,* សំណុំរឿងលេខ IT-05-88-AR65.1, សេចក្តីសម្រេចលើបណ្តឹងសាទុក្ខបន្ទាន់បង្ខំជំទាស់នឹងសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូង ដែលបដិសេធលើញត្តិរបស់ Drago Nikolić ស្នើសុំឲ្យមានការដោះលែងបណ្តោះអាសន្ន, ២៤ មករា ២០០៦, ទំព័រទី ៥។

[41] **E50/3/1/4** សេចក្តីសម្រេចលើបណ្តឹងសាទុក្ខភ្លាមៗ, ត្រង់កថាខណ្ឌ ៤៨។

[42] **E50/3/1/4** សេចក្តីសម្រេចលើបណ្តឹងសាទុក្ខភ្លាមៗ, ត្រង់កថាខណ្ឌ ៤៨។

ក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការ ជាដំណោះស្រាយមួយដ៏សមស្របសម្រាប់ហានិភ័យនៃការរត់គេចខ្លួនណាមួយនោះ គឺស្ថិតនៅលើមេធាវីការពារក្ដី។ គឺមានតែនៅក្រោយពេលដែលលក្ខខណ្ឌទាំងនេះត្រូវបានចង្អុលភស្តុតាងប៉ុណ្ណោះ ទើប គេតម្រូវឱ្យមានការវាយតម្លៃមួយទៅលើភាពគ្រប់គ្រាន់នៃការដោះលែង ដោយការដាក់ឱ្យស្ថិតនៅក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការ[43]។

២៤- កាលណាការឃុំខ្លួននៅបន្តនៅពេលសវនាការ វាត្រូវតែនៅជាសមាមាត្រជាដដែលទៅនឹងកាលៈទេសៈនៃរឿងក្ដី និងត្រូវតែមានតុល្យភាពប្រឆាំងនឹងហានិភ័យនៃការដកហូតសេរីភាពយូរ ឬមិនមានកាលកំណត់សមស្រប[44]។ សិទ្ធិជាមូលដ្ឋានចំពោះសេរីភាពបុគ្គលត្រូវតែបានថ្លឹងថ្លែងទៅនឹងមូលហេតុនានានៃការអនុញ្ញាតឱ្យមានការឃុំខ្លួន[45]។

២៥- វិធាន៨២(៤) នៃវិធានផ្ទៃក្នុង តម្រូវឱ្យមានការប្រែប្រួលនៅក្នុងកាលៈទេសៈរបស់ជនជាប់ចោទ ដើម្បីធ្វើសំណើសុំដោះលែងថ្មីមួយ បន្ទាប់ពីសំណើសុំមុនត្រូវបានបដិសេធ។ យ៉ាងណាក៏ដោយ ចំពោះពាក្យសំណើសុំមួយនេះ មេធាវីការពារក្ដីត្រូវបានអនុញ្ញាតឱ្យមានការចែករំលែកមួយពីលក្ខខណ្ឌតម្រូវនេះ ដែលជាដំណោះស្រាយមួយសម្រាប់ការជូនដំណឹងមួយដែលមិនគ្រប់គ្រាន់ ដើម្បីត្រៀមរៀបចំការដាក់សេចក្ដីសន្និដ្ឋាននានាស្ដីពីវិធាន៦៣(៣)នៃវិធានផ្ទៃក្នុង សម្រាប់ធ្វើសវនាការនៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង នៅក្នុងអំឡុងពេលនៃការដាក់សំណើពីមុន[46]។ ដំណោះស្រាយនេះត្រូវបានគាំទ្រដោយអង្គជំនុំជម្រះនេះ[47]។

## VI. **សំណុះសំណាង**

២៦- ដោយ មេធាវីការពារក្ដីខកខានមិនបានបំពេញបន្ទុករបស់ខ្លួននៅក្នុងអង្គជំនុំជម្រះសាលាដំបូង ដើម្បីបង្ហាញថាការឃុំខ្លួននោះ លែងជាការចាំបាច់ទៀតហើយ នោះមេធាវីការពារក្ដីរូបនោះ ខកខានមិន

[43] **E50/3/1/4** សេចក្ដីសម្រេចលើបណ្ដឹងសាទុក្ខភ្លាមៗ, ត្រង់កថាខណ្ឌ ៥៧។

[44] **E50/3/1/4** សេចក្ដីសម្រេចលើបណ្ដឹងសាទុក្ខភ្លាមៗ, ត្រង់កថាខណ្ឌ ៥៦។

[45] **E50/3/1/4** សេចក្ដីសម្រេចលើបណ្ដឹងសាទុក្ខភ្លាមៗ, ត្រង់កថាខណ្ឌ ៥៦, ដោយបានលើកឡើងពី *McKay ទល់នឹង ចក្រភពអង់គ្លេស,* សាលដីការបស់អង្គជំនុំជម្រះធំ, បណ្ដឹងសាទុក្ខលេខ ៥៤៣/០៣, ៣ តុលា ២០០៦, កថាខណ្ឌ ៤២។

[46] **E50** សេចក្ដីសម្រេចលើសំណើសុំដោះលែងបន្ទាន់របស់ នួន ជា, ខៀវ សំផន និង អៀង ធីរិទ្ធ, ១៦ កុម្ភៈ ២០១១, ត្រង់កថាខណ្ឌ ៤២។

[47] **E50/3/1/4** សេចក្ដីសម្រេចលើបណ្ដឹងសាទុក្ខភ្លាមៗ, ត្រង់កថាខណ្ឌ ៥១។

បានបង្ហាញនៅក្នុងបណ្តឹងសាទុក្ខនេះ ពីកំហុសណាមួយដែលសមនឹងត្រូវបានទទួលនូវដំណោះស្រាយណាស់។ ការអនុញ្ញាត ឬការបដិសេធអំពីការដោះលែងបណ្តោះអាសន្ន គឺជាសេចក្តីសម្រេចមួយដែលប្រកបទៅដោយឆន្ទានុសិទ្ធិ ដែលត្រូវបានផ្តល់ឲ្យយ៉ាងទូលំទូលាយ ហើយដោយទាក់ទិនទៅនឹងគ្រប់កាលៈទេសៈទាំងអស់ អង្គជំនុំជម្រះសាលាដំបូងបានអនុវត្តយ៉ាងត្រឹមត្រូវនូវឆន្ទានុសិទ្ធិនោះ នៅក្នុងការកំណត់ ថាតើហានិភ័យនៃភាពដែលជនជាប់ចោទអាចមកធ្វើសវនាការ មានទម្ងន់លប់លើការធានាផ្សេងៗដែលមេធាវីការពារក្តីបានដាក់ជូនមកនោះដែរ ឬទេ។

## ក. មេធាវីការពារក្តីខកខានមិនបានចង្អុលភស្តុតាងអំពីកំហុសនៅក្នុងសេចក្តីសម្រេចដែលប្រកបទៅដោយឆន្ទានុសិទ្ធិរបស់អង្គជំនុំជម្រះសាលាដំបូង

២៧- នៅពេលធ្វើការពិចារណាអំពីកាលៈទេសៈទាំងអស់ អង្គជំនុំជម្រះសាលាដំបូងបានសម្រេចថា កង្វល់ស្តីពីការធានាអំពីវត្តមានរបស់ជនជាប់ចោទនៅក្នុងអំឡុងពេលសវនាការ មិនត្រូវមានទម្ងន់លប់លើដោយការធានាផ្សេងៗដែលមេធាវីការពារក្តីបានផ្តល់ជូននោះទេ។ មេធាវីការពារក្តីបានលើកឡើងថា អង្គជំនុំជម្រះសាលាដំបូងមានកំហុសឆ្គងនៅក្នុងការដែលខ្លួនបានដាក់ទម្ងន់ឲ្យទៅលើកត្តានានា ដែលទាក់ទងទៅនឹងការឃុំខ្លួនបណ្តោះអាសន្ន ដោយឡែកគឺកង្វល់របស់ខ្លួនអំពីហានិភ័យនៃការរត់គេចខ្លួនរបស់ជនជាប់ចោទ[48]។ មេធាវីការពារក្តីក៏បានចោទប្រកាន់ផងដែរថា អង្គជំនុំជម្រះសាលាដំបូង "មិនបានផ្តល់អំណះអំណាងគ្រប់គ្រាន់ នៅក្នុងសេចក្តីសម្រេចរបស់ខ្លួនទេ"[49]។

២៨- អង្គជំនុំជម្រះនេះ ដោយខ្លួនឯង ធ្លាប់បានរកឃើញថា "ហានិភ័យរបស់ជនជាប់ចោទក្លាយទៅជាមិនមានលទ្ធភាពសម្រាប់សវនាការ" បានធ្វើយុត្តិកម្មលើការឃុំខ្លួនបណ្តោះអាសន្នរបស់ជនជាប់ចោទ[50]។ អំណះអំណាងរបស់មេធាវីការពារក្តី មិនបានបង្ហាញថា អង្គជំនុំជម្រះសាលាដំបូង ឬមួយក៏ អង្គជំនុំជម្រះនេះ មានកំហុសនៅក្នុងសេចក្តីសន្និដ្ឋាននោះទេ។ យ៉ាងណាក៏ដោយ បើអង្គជំនុំជម្រះនេះត្រូវបានធ្វើឲ្យជឿថា អង្គជំនុំជម្រះសាលាដំបូងបានប្រព្រឹត្តនូវកំហុសនៅក្នុងសម្អាងហេតុរបស់ខ្លួន ស្តីពីយុត្តិកម្មសម្រាប់ការឃុំខ្លួនបណ្តោះអាសន្ន កាលណាមាន "មូលដ្ឋានផ្លូវច្បាប់ សម្រាប់ការរក្សាទុកជន

[48] **E275/2/1** បណ្តឹងសាទុក្ខ, គ្រង់កថាខណ្ឌ ១៤។

[49] **E275/2/1** បណ្តឹងសាទុក្ខ, គ្រង់កថាខណ្ឌ ១៤។

[50] **E50/3/1/4** សេចក្តីសម្រេចលើបណ្តឹងសាទុក្ខភ្លាមៗ, គ្រង់កថាខណ្ឌ ៥២។

ជាប់ចោទក្នុងការឃុំបណ្ដោះអាសន្ន [តាមវិធាន ៦៣(៣)(ខ)(iii) នៃវិធានផ្ទៃក្នុង] នៅតែមានសុពលភាព"[51] នោះអង្គជំនុំជម្រះនេះ "អាចដាក់សម្អាងហេតុជំនួសសម្អាងហេតុដែលខុសឆ្គងនៃសេចក្ដីសម្រេចរបស់តុលាការសាលាដំបូងបាន"[52]។

២៩- ដោយហេតុថា កត្តាទាំងឡាយដែលគាំទ្រដល់សេចក្ដីសន្និដ្ឋាន ដែលកង្វល់អំពីវត្តមានរបស់ជនជាប់ចោទនៅពេលសវនាការ បានធ្វើយុត្តិកម្មលើការបន្តឃុំខ្លួន នោះអង្គជំនុំជម្រះសាលាដំបូងបានពិចារណាថាជា "ការពិចារណាជាបឋម" លើហានិភ័យនៃការរត់គេចខ្លួនរបស់ជនជាប់ចោទ។ យ៉ាងណាក៏ដោយ បន្ថែមលើនេះ គេបានពិចារណាផងដែរអំពីផលប៉ះពាល់ទៅលើសវនាការ ដែលថាការមិនបង្ហាញខ្លួនរបស់ជនជាប់ចោទ នៅដំណាក់កាលចុងក្រោយនៃសវនាការ មុខជានឹងមានភាពស្មុគស្មាញនៅក្នុងសវនាការ និងមានកាលៈទេសៈជាសក្ដានុពលស្ដីពីអវត្តមានដោយអចេតនាជាមិនខាន[53]។

៣០- មេធាវីការពារក្ដីបានស្វែងរកធ្វើការចង្អុលភស្ដុតាងពីកំហុស ដោយធ្វើការយោងទៅដល់សេចក្ដីបង្គាប់របស់អង្គជំនុំជម្រះនេះថា សក្ដានុពលនៃការកាត់ឲ្យជាប់ទោសយូរ មិនអាចជា "កត្តាតែមួយគត់ក្នុងការកំណត់ពីលទ្ធផលនៃពាក្យស្នើសុំដោះលែង"នោះឡើយ[54]។ យ៉ាងណាក៏ដោយ វាច្បាស់លាស់ណាស់ដែលថា ការកាត់ឲ្យជាប់ទោសយូរអង្វែងជាសក្ដានុពលរបស់ជនជាប់ចោទ គឺជាកត្តាតែមួយគត់ដែលបានបញ្ជាក់អំពីហានិភ័យនៃការរត់គេចខ្លួន អ្វីផ្សេងៗទៀតនោះ គឺជាដំណាក់កាលជឿនលឿនទៅមុខនៃសវនាការ។ លើសពីនេះ ហានិភ័យនៃការរត់គេចខ្លួន គឺជាកត្តាតែមួយគត់ក្នុងចំណោមកត្តានានា ដែលអង្គជំនុំជម្រះសាលាដំបូងបានពិចារណាថាជាការប្រឆាំងទល់នឹងការដោះលែងបណ្ដោះអាសន្ន។ អង្គជំនុំជម្រះនេះ ដោយខ្លួនឯង បានកត់សម្គាល់ថា ផលប៉ះពាល់ដែលធ្វើឲ្យខូចប្រយោជន៍ ចេញមកពីអវត្តមានរបស់ជនជាប់ចោទនោះ គឺបើសិនជា "ទៅលាក់ខ្លួន សម្រេចចិត្តមិនគោរពតាមដីកាកោះ, ឬក៏អាចនឹងត្រូវបានរារាំងជាបណ្ដោះអាសន្ន មិនឲ្យចូលរួមក្នុងសវនាការ"[55]។ ទោះបី "គឺជាការសមហេតុសមផលមួយដែល អង្គជំនុំជម្រះសាលាដំបូង ត្រូវធ្វើការពិចារណាអំពី

---

[51] **E50/3/1/4** សេចក្ដីសម្រេចលើបណ្ដឹងសាទុក្ខភ្លាមៗ, ត្រង់កថាខណ្ឌ ៥៤។

[52] **E50/3/1/4** សេចក្ដីសម្រេចលើបណ្ដឹងសាទុក្ខភ្លាមៗ, ត្រង់កថាខណ្ឌ ៥២។

[53] **E275/1** សេចក្ដីសម្រេចដែលរងការជំទាស់, ត្រង់កថាខណ្ឌ ២១។

[54] **E50/3/1/4** សេចក្ដីសម្រេចលើបណ្ដឹងសាទុក្ខភ្លាមៗ, ត្រង់កថាខណ្ឌ ៤០។

[55] **E50/3/1/4** សេចក្ដីសម្រេចលើបណ្ដឹងសាទុក្ខភ្លាមៗ, ត្រង់កថាខណ្ឌ ៥៤។

ភាពធ្ងន់ធ្ងរនៃឧក្រិដ្ឋកម្មដែលចោទប្រកាន់"[56] យ៉ាងណាក៏ដោយ ក៏អង្គជំនុំជម្រះសាលាដំបូងមិនបានយល់ឃើញពី "លទ្ធភាពនៃភាពធ្ងន់ធ្ងរអំពីការកាត់ឲ្យជាប់ទោស ថាមានលក្ខណៈដាច់ស្រេច" នោះដែរ[57]។ ទាំងមេធាវីការពារក្តីក៏មិនបានចង្អុល ភស្តុតាងលើការអះអាងមួយដែលថា អង្គជំនុំជម្រះសាលាដំបូងបានដាក់ទម្ងន់ជ្រុលហួសហេតុទៅលើហានិភ័យនៃការរត់គេចខ្លួនរបស់ជនជាប់ចោទ។ អង្គជំនុំជម្រះនេះធ្លាប់បានបញ្ជាក់អះអាងថា លទ្ធភាពនៃការកាត់ឲ្យជាប់ទោសយូរអង្វែង គឺជាកត្តាមួយដែលពាក់ព័ន្ធទៅនឹងហានិភ័យនៃការរត់គេចខ្លួន ហើយអង្គជំនុំជម្រះសាលាដំបូងត្រូវបានផ្តល់ឆន្ទានុសិទ្ធិទូលំទូលាយនៅក្នុងការពិចារណាអំពីទម្ងន់ដែលត្រូវផ្តល់ឲ្យទៅកត្តាផ្សេងៗ ដែលមានការពាក់ព័ន្ធទៅនឹងថា តើត្រូវបន្តការឃុំខ្លួនទៀត ឬមួយយ៉ាងណា។ អាស្រ័យហេតុដូច្នេះ សេចក្តីសម្រេចដែលរងការជំទាស់នេះ មិនបំពានលើសេចក្តីណែនាំរបស់អង្គជំនុំជម្រះដែលពាក់ព័ន្ធនឹងរឿងនេះទេ។

៣១- នៅក្នុងការប៉ុនប៉ងបង្ហាញអំពីកំហុសឆ្គងនេះ មេធាវីការពារក្តីក៏បានលើកឡើងចោទប្រកាន់ផងដែរថា៖ អង្គជំនុំជម្រះសាលាដំបូងមិនបាន "ពិចារណាទៅលើអង្គហេតុដែលថា លោក ខៀវ សំផន ពុំមានមធ្យោបាយខាងសម្ភារៈសម្រាប់ឲ្យគាត់អាចរត់គេចខ្លួនបាននោះឡើយ"[58]។ ការរកឃើញរបស់អង្គជំនុំជម្រះសាលាដំបូង ដែលថា ការធានាទាំងឡាយដែលបានផ្តល់ឲ្យដោយជនជាប់ចោទ និងសមាជិកក្រុមគ្រួសាររបស់គាត់ គឺមិនគ្រប់គ្រាន់ទេនៅក្នុងកាលៈទេសៈនេះ "គឺជារឿងមួយខុសឆ្គងសុទ្ធសាធ"[59] ហើយអង្គជំនុំជម្រះសាលាដំបូងបាន "ច្រានចោលតថភាពជាក់ស្តែង ព្រមទាំងការ ធានាហ្មឹងហ្មាត់របស់ជនជាប់ចោទ និងក្រុមគ្រួសារជនជាប់ចោទ"[60]។

៣២- ជាបញ្ហាខាងអង្គហេតុ អំណះអំណាងរបស់មេធាវីការពារក្តីដែលពាក់ព័ន្ធនឹង "ពុំមានមធ្យោបាយខាងសម្ភារៈសម្រាប់ឲ្យគាត់អាចរត់គេចខ្លួនបាននោះឡើយ" គឺមិនត្រូវបានគេយល់ដូច្នោះទេ។ អង្គជំនុំជម្រះនេះបានសម្រេចថា "សូម្បីតែករណីតែមួយគត់ដែលជនចាប់ចោទខកខានមិនបង្ហាញខ្លួននៅ

---

[56] **E50/3/1/4** សេចក្តីសម្រេចលើបណ្តឹងសាទុក្ខភ្នាម១, ត្រង់កថាខណ្ឌ ៤០។

[57] *រដ្ឋអាជ្ញា ទល់នឹង Čermak និង Mladen Markač,* សំណុំរឿងលេខ IT-03-73-AR65.1, សេចក្តីសម្រេចលើបណ្តឹងសាទុក្ខបន្ទាន់បង្ខំជំទាស់នឹងសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូង ដែលបដិសេធលើការដោះលែងបណ្តោះអាសន្ន, ២ ធ្នូ ២០០៤, កថាខណ្ឌ ២៧ (បានលើកឡើងដោយអង្គជំនុំជម្រះតុលាការកំពូល នៅត្រង់ **E50/3/1/4** សេចក្តីសម្រេចលើបណ្តឹងសាទុក្ខភ្នាម១, ត្រង់កថាខណ្ឌ ៤១)។

[58] **E275/2/1** បណ្តឹងសាទុក្ខ, ត្រង់កថាខណ្ឌ ២៣។

[59] **E275/2/1** បណ្តឹងសាទុក្ខ, ត្រង់កថាខណ្ឌ ៣១។

[60] **E275/2/1** បណ្តឹងសាទុក្ខ, ត្រង់កថាខណ្ឌ ៣៥។

ចំពោះមុខតុលាការ អាចនឹងធ្វើឲ្យមហន្តរាយដល់លទ្ធភាពនៃការចេញសាលក្រម ក្នុងរយៈពេលវេលាសមស្រប"[61] ហើយវាជាក់ស្តែងដោយខ្លួនឯងដែលថា វាមិនមានការចាំបាច់អ្វី ត្រូវមានលិខិតឆ្លងដែន មធ្យោបាយហិរញ្ញវត្ថុផ្ទាល់ខ្លួន ឬកម្លាំងកាយបរិបូណ៌[62] ដើម្បីធ្វើការរត់គេចខ្លួននោះទេ សូម្បីតែមួយរយៈពេលខ្លីក៏ដោយ។

៣៣- ប៉ុន្តែអង្គជំនុំជម្រះសាលាដំបូងមិនត្រឹមតែមានកង្វល់ពីអវត្តមានដោយចេតនា ដែលអាចនឹងមានការរំខានដល់សវនាការប៉ុណ្ណោះទេ ថែមទាំងមានកង្វល់ពីអវត្តមានដោយអចេតនាទៀតផង[63]។ ទាក់ទងទៅនឹងកង្វល់ទាងនេះ ខ្លួនបានបដិសេធ "ការធានាអះអាងរបស់ជនជាប់ចោទ និងសមាជិកគ្រួសារ" ដែលបានពិចារណាយ៉ាងសមហេតុសមផល ដើម្បីបញ្ចូលនូវលក្ខខណ្ឌនៃការដាក់ឲ្យស្ថិតនៅក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការដែលបានស្នើសុំជាផ្លូវការ[64] ថាមិនគ្រប់គ្រាន់ក្នុងការដាក់ទម្ងន់ឲ្យលប់លើកង្វល់របស់ខ្លួនដែលពាក់ព័ន្ធនឹងលទ្ធភាពនៃការមិនចូលខ្លួនរបស់គាត់[65]។ ការរកឃើញនេះ គឺនៅក្នុងឆន្ទានុសិទ្ធិរបស់អង្គជំនុំជម្រះសាលាដំបូងទាំងស្រុង ហើយជាការសមហេតុសមផលក្នុងការពិចារណាពីកាលៈទេសៈនៃរឿងក្តីនេះ។ នៅក្នុងវិសាលភាពដែលអង្គជំនុំជម្រះសាលាដំបូង ពិតជាមានការផ្តល់មិនត្រឹមត្រូវអំពីការធានាដែលបានស្នើសុំជាផ្លូវការ នោះជាការច្បាស់លាស់ណាស់ "សម្រាប់ឲ្យអង្គជំនុំជម្រះសាលាដំបូងធ្វើការពិចារណាអំពីភាពជឿជាក់នៃគ្រប់ភ័ស្តុតាងទាំងអស់ដែលបានដាក់បង្ហាញ។ ... [អង្គជំនុំជម្រះសាលាដំបូង] មានសិទ្ធិនៅក្នុងការឈានដល់សេចក្តីសន្និដ្ឋានមួយដែលផ្ទុយគ្នាទៅនឹងសេចក្តីសន្និដ្ឋានដែលត្រូវបានដាក់ពីសំណាក់[ភាគីដាក់បណ្តឹង] បន្ទាប់ពីបានធ្វើការពិចារណាលើព័ត៌មានដែលគេបានដាក់បង្ហាញដល់ខ្លួន"[66]។

---

[61] **E50/3/1/4** សេចក្តីសម្រេចលើបណ្តឹងសាទុក្ខភ្លាមៗ, ត្រង់កថាខណ្ឌ ៥៥។

[62] សូមអាន **E275/2/1** បណ្តឹងសាទុក្ខ, ត្រង់កថាខណ្ឌ ២៥។

[63] **E275/1** សេចក្តីសម្រេចដែលរងការជំទាស់, ត្រង់កថាខណ្ឌ ២១។

[64] សូមអាន **E275/1** សេចក្តីសម្រេចដែលរងការជំទាស់, ត្រង់កំណត់សម្គាល់ជើងទំព័រលេខ ៤២, ៤៣។

[65] **E275/1** សេចក្តីសម្រេចដែលរងការជំទាស់, ត្រង់កថាខណ្ឌ ២១។ សូមអានផងដែរ *រដ្ឋអាជ្ញា ទល់នឹង Zdravko Tolimir និងគូកន,* សេចក្តីសម្រេចលើបណ្តឹងសាទុក្ខបន្ទាន់បង្កំជំទាស់នឹងសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូង ដែលអនុញ្ញាតឲ្យមានការដោះលែងបណ្តោះអាសន្ន, ១៩ តុលា ២០០៥, កថាខណ្ឌ ២៩ (យោងជាទូទៅ "អាចត្រូវបានយល់ថាមានការដាក់បញ្ចូល" នូវអង្គហេតុជាក់លាក់នានាដែលទាក់ទងទៅនឹងការដោះលែងបណ្តោះអាសន្ន)។

[66] *រដ្ឋអាជ្ញា ទល់នឹង Zdravko Tolimir និងគូកន,* សេចក្តីសម្រេចលើបណ្តឹងសាទុក្ខបន្ទាន់បង្កំជំទាស់នឹងសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូង ដែលអនុញ្ញាតឲ្យមានការដោះលែងបណ្តោះអាសន្ន, ១៩ តុលា ២០០៥, កថាខណ្ឌ ១៥។

៣៤- រីឯការប្តឹងតវ៉ាជាទូទៅរបស់មេធាវីការពារក្តីដែលថា សេចក្តីសម្រេចមិនមានសម្អាងហេតុគ្រប់គ្រាន់នោះ សហព្រះរាជអាជ្ញាសន្និដ្ឋានថា សេចក្តីពន្យល់របស់អង្គជំនុំជម្រះសាលាដំបូង ស្តីពីកត្តាផ្សេងៗដែលខ្លួនបានរកឃើញនោះ គឺបានគាំទ្រដល់សេចក្តីសម្រេចរបស់ខ្លួន ហើយដែលភាគច្រើននៃកត្តាទាំងនោះដែលខ្លួនមិនបានពន្យល់ គឺមានសម្អាងហេតុគ្រប់គ្រាន់។ សហព្រះរាជអាជ្ញាបានកត់សម្គាល់ថា "អង្គជំនុំជម្រះសាលាដំបូង គឺ "មិនមានកាតព្វកិច្ចត្រូវដោះស្រាយគ្រប់កត្តាដែលអាចមានទាំងអស់ដែលអង្គជំនុំជម្រះសាលាដំបូងអាចយកមកពិចារណានៅពេលធ្វើការសម្រេចថា បើត្រូវបានដោះលែង តើខ្លួនយល់ឃើញថាជនជាប់ចោទរូបនោះ នឹងមកបង្ហាញខ្លួននៅពេលសវនាការដែរ ឬទេ។ ជាការគ្រប់គ្រាន់សម្រាប់អង្គជំនុំជម្រះសាលាដំបូងក្នុងការចង្អុលបញ្ជាក់ថា គ្រប់កត្តាពាក់ព័ន្ធទាំងអស់ខ្លួនបានយកមកពិចារណានៅក្នុងការឈានដល់សេចក្តីសម្រេចរបស់ខ្លួន។ និយាយម្យ៉ាងទៀត អង្គជំនុំជម្រះសាលាដំបូងត្រូវតែចេញសេចក្តីសម្រេចដែលមានសំអាងហេតុ"[67]។ អង្គជំនុំជម្រះសាលាដំបូងធ្លាប់បានបដិសេធពីមុនលើអំណះអំណាងរបស់មេធាវីការពារក្តី ដែលពួកគាត់បានលើកឡើងម្តងទៀតនៅក្នុងបណ្តឹងសាទុក្ខនេះ[68] ដែលថាសេចក្តីសម្រេចមួយរបស់អង្គជំនុំជម្រះសាលាដំបូងស្តីពីការឃុំខ្លួនបណ្តោះអាសន្ន គួរតែត្រូវបានទុកជាមោឃៈ ដោយមកពីមិនមានសម្អាងហេតុគ្រប់គ្រាន់ ដែលមានមូលដ្ឋាននៅលើសេចក្តីសម្រេចនានាដែលធ្វើឡើងដោយ *តុលាការសាលាវិនិច្ឆ័យ* របស់ប្រទេសបារាំង ពីព្រោះវា "មិនមានការទាក់ទងគ្នាទេ តាមស្មារតីវិធាន ៨២(១) នៃវិធានផ្ទៃក្នុង"[69]។ សូម្បីតែ អង្គជំនុំជម្រះតុលាការកំពូលចង់បានភ័ស្តុតាងបន្ថែមទៀត ដើម្បីយកមកចង្អុលជាភ័ស្តុតាងពីភាពចាំបាច់នៃការបន្តឃុំខ្លួនជនជាប់ចោទនោះ ខ្លួនមុខជានឹងរកវាឃើញនៅក្នុងសេចក្តីសន្និដ្ឋាននានារបស់សហព្រះរាជអាជ្ញា ដែលមាននៅក្នុងកំណត់ត្រា[70] ដែលដាក់ជូនទៅអង្គជំនុំជម្រះសាលាដំបូង ស្តីពីកត្តាទាំងអស់ក្នុងវិធាន ៦៣(៣)(ខ) នៃវិធានផ្ទៃក្នុង[71]។ ភ័ស្តុតាងនោះ រួមមាន៖ ក) ហានិភ័យចំពោះសន្តិសុខរបស់ជនជាប់ចោទ ដែលកើតឡើងពីការបង្ហាញខ្លួនរបស់គាត់នៅក្នុងការធ្វើដំណើរទៅ និងមកពីអង្គជំនុំ

---

[67] *ព្រះរាជអាជ្ញា ទល់នឹង Jovica Stanisic,* សំណុំរឿងលេខ IT-03-69-PT, សេចក្តីសម្រេចលើការដោះលែងបណ្តោះអាសន្ន, ២៨ កក្កដា ២០០៤, កថាខណ្ឌ ១០ (សម្រង់សម្តីផ្ទៃក្នុងត្រូវបានលុបចោល)។

[68] **E275/2/1** បណ្តឹងសាទុក្ខ, ត្រង់កថាខណ្ឌ ៣៩។

[69] **E50/3/1/4** សេចក្តីសម្រេចលើបណ្តឹងសាទុក្ខភ្លាមៗ, ត្រង់កំណត់សម្គាល់ជើងទំព័រលេខ ៨៤។

[70] **E1/180.1** ប្រតិចារឹក, ១១ មេសា ២០១៣, ត្រង់ទំព័រទី ១១២-១១៧។

[71] **E50/3/1/4** សេចក្តីសម្រេចលើបណ្តឹងសាទុក្ខភ្លាមៗ, ត្រង់កថាខណ្ឌ ៥៤។ **E1/180.1** ប្រតិចារឹក, ១១ មេសា ២០១៣, ទំព័រទី ១១៤ ("យើងខ្ញុំយល់ស្របជាមួយនឹងតុលាការកំពូល គឺបានរកឃើញទាំងពីហានិភ័យដែលមិនអាចទទួលយកបាន ទាំងពីសន្តិសុខសម្រាប់លោក ខៀវ សំផន ផ្ទាល់។ លើសពីនេះទៅទៀត នៅលើវិធាន ៦៣(៣)(ខ)(iii) ដែលទាក់ទងទៅនឹងវត្តមានរបស់គាត់។ វាអាចបង្កហានិភ័យដែលមិនអាចទទួលយកបានផងដែរ ដែលថាអាចនឹងមិនធានាទៅដល់វត្តមានរបស់គាត់ទេ បើគាត់ទទួលបាននូវការដោះលែងមែននោះ")។

ជម្រះ ដើម្បីសវនាការដែលបានរៀបចំកាលវិភាគរួចហើយ, ខ) ភស្តុតាងនៃការស្ទាបស្ទង់មតិជាសាធារណៈដែលបានបញ្ជាក់ថា ជនរងគ្រោះមួយចំនួនធំនៅមានអារម្មណ៍សងសឹកចំពោះជនជាប់ចោទនៅឡើយ, គ) ការវាយប្រហារពីមុនៗទៅលើជនជាប់ចោទ និងការទទួចរបស់គាត់ផ្ទាល់ស្តីពីការធានារក្សាសន្តិសុខ, ឃ) ការបង្ហាញខ្លួនយ៉ាងទូលំទូលាយនៅក្នុងតួនាទីរបស់ជនជាប់ចោទក្នុងបក្សកុម្មុយនីសកម្ពុជា និងក្នុងរបបកម្ពុជាប្រជាធិបតេយ្យដែលគេបានស្តាប់ដោយចំហរនៅក្នុងអង្គជំនុំជម្រះ, ង) សេចក្តីថ្លែងពីមុនៗរបស់ជនជាប់ចោទ ដែលបានសួរពីធម្មានុភាពនៃកិច្ចដំណើរការរបស់អវតក និងដែលបានជំទាស់ទៅនឹងអនាគតនៃការជំនុំជម្រះក្តីលើរូបគាត់[72]។

## ខ. មេធាវីការពារក្តីខកខានមិនបានបង្ហាញភស្តុតាងអំពីកំហុសនៅក្នុងការសន្និដ្ឋានចុងក្រោយរបស់អង្គជំនុំជម្រះសាលាដំបូង ដែលថាការឃុំខ្លួនជនជាប់ចោទមិនមានវិសមាមាត្រទៅនឹងកាលៈទេសៈនោះឡើយ

៣៥- មេធាវីការពារក្តីតវ៉ាថា អង្គជំនុំជម្រះសាលាដំបូងបានប្រព្រឹត្តកំហុសអង្គច្បាប់ ដោយសារតែអង្គជំនុំជម្រះនេះមិនបានដាក់បញ្ចូលដំណាក់កាលស៊ើបសួរ ក្នុងការគណនាពីរយៈពេលនៃការឃុំខ្លួនបណ្តោះអាសន្ន អាស្រ័យហេតុនេះទើបមិនបានដាក់បញ្ចូលនៅ “កាលៈទេសៈដែលពាក់ព័ន្ធ”[73]។ មេធាវីការពារក្តីក៏តវ៉ាផងដែរថា អង្គជំនុំជម្រះសាលាដំបូង“ខកខានមិនបានគិតគូរអំពីសេចក្តីសន្និដ្ឋានរបស់មេធាវីការពារក្តី ឬផ្តល់មូលហេតុណាមួយចំពោះសេចក្តីសម្រេចរបស់ខ្លួននៅក្នុងនោះឡើយ”[74]។

---

[72] **E1/180.1** ប្រតិចារឹក, ១១ មេសា ២០១៣, ត្រង់ទំព័រទី ១១២-១១៧។ សហព្រះរាជអាជ្ញាក៏បានដាក់សេចក្តីសន្និដ្ឋានជូនដល់អង្គជំនុំជម្រះតុលាការកំពូល សម្រាប់ជាការពិចារណាផងដែរ នូវការស្ទាបស្ទង់មតិនាពេលថ្មីៗនេះ ដែលមានទំនោរក្នុងការអះអាងពីអត្ថិភាពនៃហានិភ័យរបស់ជនជាប់ចោទ (ឯកសារទាំងនេះត្រូវបានបញ្ជូនទៅឱ្យអង្គជំនុំជម្រះសាសលាដំបូង និង មេធាវីការពារក្តី នៅមុនសវនាការស្តីពីសំណើសុំដោះលែង។ ឯកសារទាំងនេះ មិនត្រូវបានដាក់ជូនទេ ដោយមកពីអង្គជំនុំជម្រះសាសលាដំបូង បានបង្គាប់ទៅសហព្រះរាជអាជ្ញា ថាកុំឱ្យដាក់ចម្លើយតបជាលាយលក្ខណ៍អក្សរតបទៅនឹងសំណើសុំដោះលែង)៖ មជ្ឈមណ្ឌលសិទ្ធិមនុស្ស, សាកលវិទ្យាល័យកាលីហ្វ័រនីយ៉ា, Berkley, *បន្ទាប់ពីសវនាការលើកទីមួយ - ការស្ទាបស្ទង់មតិដែលមានមូលដ្ឋាននៅលើប្រជាជន និងការយល់ឃើញពីយុត្តិធម៌ និង អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា,* ខែមិថុនា ឆ្នាំ២០១១ (សូមអាន ទំព័រទី ៥ ចំណុចទី ៣)។ មជ្ឈមណ្ឌលប៉េីរឡាំងសម្រាប់ប្រព្រឹត្តកម្មលើជនរងគ្រោះដែលទទួលរងនូវអំពើទារុណកម្ម, *សម្លេងរបស់អ្នកដែលនៅរស់រានមានជីវិត៖ អាកប្បកិរិយានៅ អវតក, អតីតខ្មែរក្រហម និងបទពិសោធន៍ជាមួយនឹងការចូលរួមរបស់ដើមបណ្តឹងរដ្ឋប្បវេណី,* ខែធ្នូ ឆ្នាំ២០១០ (សូមអាន ក្រាហ្វលេខ ២ និង ៣ នៅទំព័រទី ៣០-៣១)។

[73] **E275/2/1** បណ្តឹងសាទុក្ខ, ត្រង់កថាខណ្ឌទី៥១ (សម្រង់ខាងក្នុង និងន័យសរសេរជាអក្សរទ្រេត ត្រូវបានលប់)។

[74] **E275/2/1** បណ្តឹងសាទុក្ខ, ត្រង់កថាខណ្ឌទី៥២។

៣៦- ផ្ទុយពីការអះអាងរបស់មេធាវីការពារក្តី អង្គជំនុំជម្រះសាលាដំបូងពិតជាបាន "ផ្តល់នូវមូលហេតុចំពោះសេចក្តីសម្រេចរបស់ខ្លួន"[75] ក្នុងការច្រានចោលអំណះអំណាងដែលធ្វើឡើងដោយមេធាវីការពារក្តី ដោយមានការពន្យល់ថា ករណីយុត្តិសាស្ត្រអន្តរជាតិ ភាពស្មុគស្មាញនៃរឿងក្តី និងល្បឿនដែលបានដំណើរការនៅក្នុងចំណោម "កាលៈទេសៈពាក់ព័ន្ធទាំងអស់" ដែលទាំងអស់នេះបានគាំទ្រចំពោះសេចក្តីសម្រេចរបស់ខ្លួន[76]។ ជាផ្នែកនៃការវិភាគនោះ អង្គជំនុំជម្រះសាលាដំបូងបានធ្វើការប្រៀបធៀបនូវថិរវេលានៃការឃុំខ្លួនក្នុងករណីនេះ ជាមួយនឹងករណីទាំងឡាយដែលបានជំនុំជម្រះនៅចំពោះមុខតុលាការ*ពិសេស* នានា។ មេធាវីការពារក្តីទាមទារថា នេះជាការភាន់ច្រឡំមួយដោយហេតុថា "កិច្ចដំណើរការនីតិវិធីតទល់នៅចំពោះមុខតុលាការ ICTY ICTR និង ICC មានរយៈពេលវែងចាំបាច់ច្រើនជាងកិច្ចដំណើរការនីតិវិធីដែលចាប់ផ្តើមធ្វើមុនដោយកិច្ចស៊ើបសួរ"[77] និងបានចោទប្រកាន់អង្គជំនុំជម្រះសាលាដំបូងថាមាន "បំណងអាក្រក់ត្រង់ៗ"[78] ក្នុងការធ្វើដូច្នេះ។ ការធ្វើការសន្និដ្ឋានដូច្នេះ គឺពុំមានអង្គសេចក្តីទេ។ ទីមួយ ដូចបានកត់សម្គាល់ខាងលើ អង្គជំនុំជម្រះសាលាដំបូងបានពិចារណាទាំងរយៈពេលនៃការឃុំខ្លួនមុនសវនាការ និងការឃុំខ្លួនក្នុងពេលសវនាការ ដើម្បីធ្វើការប្រៀបធៀប ដូច្នេះដើម្បីជៀសវៀងភាពខុសគ្នាដូចដែលបានចោទប្រកាន់រវាងតុលាការនិមួយៗ។ ទីពីរ សហព្រះរាជអាជ្ញាបានធ្វើការកត់សម្គាល់ជូនអង្គជំនុំជម្រះសាលាដំបូងថា ករណីរឿងក្តីនានានៅចំពោះមុខតុលាការ*ពិសេស* តាមពិតគឺមិនស្រដៀងគ្នានឹងករណីនេះទេ ក្រៅតែពីរឿងក្តីនានារបស់តុលាការសិទ្ធិមនុស្សអឺរ៉ុប ដែលមេធាវីការពារក្តីបានលើកនៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង[79] (ប៉ុន្តែមិនបានពឹងផ្អែកក្នុងបណ្តឹងសាទុក្ខនេះទេ) ដោយសារ តុលាការអន្តរជាតិ ពាក់ព័ន្ធនឹង"ករណីឧក្រិដ្ឋកម្មធំៗ មិនមែនជាករណីក្នុងស្រុកដែលពាក់ព័ន្ធនឹងបទចោទតែមួយដូចជា មនុស្សឃាត ឬអំពើប្លន់ ឬអំពើឆបោកតែមួយករណី"[80]ឡើយ។ ពាក់ព័ន្ធនឹងចំណុចនេះ សហព្រះរាជអាជ្ញាបានធ្វើការកត់សម្គាល់ថា ក្នុងចំណោមរឿងក្តីជាង៥០ នៅតុលាការ ICTY ជនជាប់ចោទត្រូវបានឃុំខ្លួនក្នុង

---

[75] **E275/2/1** បណ្តឹងសាទុក្ខ, ត្រង់កថាខណ្ឌទី៥២។

[76] **E275/1** សេចក្តីសម្រេចដែលរងការជំទាស់, ត្រង់កថាខណ្ឌទី២៣។

[77] **E275/2/1** បណ្តឹងសាទុក្ខ, ត្រង់កថាខណ្ឌទី៥៧។

[78] **E275/2/1** បណ្តឹងសាទុក្ខ, ត្រង់កថាខណ្ឌទី៥៧។

[79] **E275** សំណើសុំដោះលែងលោក ខៀវ សំផន ឲ្យនៅក្រៅឃុំជាបន្ទាន់ដោយដាក់ឲ្យស្ថិតក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការ, ២៩ មីនា ២០១៣, កំណត់សម្គាល់ចុងទំព័រលេខ២១, ២២។

[80] **E1/180.1** ប្រតិចារឹក, ១១ មេសា ២០១៣ ត្រង់ទំព័រទី១០៣។

រយៈពេលប្រាំឆ្នាំ ឬវែងជាងនេះ ចំណែកនៅតុលាការ ICTR ជនជាប់ចោទត្រូវបានឃុំខ្លួនក្នុងរយៈពេលប្រាំឆ្នាំ ឬវែងជាងនេះ ក្នុងរឿងក្ដីច្រើនជាង៣១[81]។

៣៧- អង្គជំនុំជម្រះសាលាដំបូងបានបញ្ជាក់យ៉ាងច្បាស់ពីថិរវេលានៃឃុំខ្លួនមុនសវនាការ ក្នុងការគណនារបស់ខ្លួនពីថិរវេលានៃការឃុំខ្លួនបណ្ដោះអាសន្ន។ អង្គជំនុំជម្រះសាលាដំបូងបានធ្វើការកត់សម្គាល់យ៉ាងច្បាស់ថា "អនុលោមតាមយុត្តិសាស្ត្ររបស់ ECtHR ការឃុំខ្លួនមុនពេលសវនាការ គិតចាប់ពីពេលដែលបុគ្គលណាម្នាក់ ត្រូវបានបញ្ជូនមកដាក់ឲ្យស្ថិតក្នុងការឃុំឃាំង"[82]។ ជាការបន្ថែម អង្គជំនុំជម្រះសាលាដំបូងបានស្វែងការណែនាំអំពី "ករណីនានាដែលមានភាពស្មុគស្មាញអាចប្រៀបធៀបគ្នាបាន" ដែលមាន "ការឃុំខ្លួនបណ្ដោះអាសន្នចាប់ពីប្រាំឆ្នាំ ឬលើសពីនេះ"[83]។ អង្គជំនុំជម្រះសាលាដំបូងកត់សម្គាល់ថា ដោយរាប់បញ្ចូលទាំងថិរវេលានៃការឃុំខ្លួនមុនសវនាការ ជនជាប់ចោទបានជាប់ឃុំឃាំងអស់រយៈពេលប្រាំឆ្នាំ និងប្រាំខែ គិតមកដល់ពេលដែលសេចក្ដីសម្រេចដែលរងការជំទាស់បានចេញ ដូច្នេះបញ្ជាក់ច្បាស់ថា អង្គជំនុំជម្រះសាលាដំបូងបានដាក់បញ្ចូលថិរវេលានៃការឃុំខ្លួនមុនសវនាការនៅក្នុងការគណនារបស់ខ្លួន។

៣៨- ជាងនេះទៀត ការអះអាងរបស់មេធាវីការពារក្ដីដែលថា អង្គជំនុំជម្រះសាលាដំបូងមិនបានគិតគូពីសេចក្ដីសន្និដ្ឋានរបស់ខ្លួន អំពីការពន្យារពេល និងកង្វះការព្យាយាមដូចដែលខ្លួនបានអះអាង នៅក្នុងអំឡុងពេលនៃដំណាក់កាលស៊ើបសួរ គឺមិនមានអង្គសេចក្ដីទេ។ ដោយទុកជាបញ្ហាទូទៅមួយ ការពិតដែលអង្គជំនុំជម្រះមិនបាននិយាយឲ្យច្បាស់ចំពោះអំណះអំណាងទាំងអស់ ដែលបានលើកឡើងដោយភាគីមួយ "មិនមែនមានន័យថា អង្គជំនុំជម្រះនេះមិនបានគិតគូរដែលបានលើកឡើងដោយភាគីមួយ "មិនមែនមានន័យថា អង្គជំនុំជម្រះនេះមិនបានគិតគូរ[ចំពោះបញ្ហា]នោះឡើយ[84]។ តាមពិត អង្គជំនុំតុលាការកំពូលបានសម្រេចថា "អង្គជំនុំជម្រះសាលាដំបូងមិនតម្រូវឲ្យបង្ហាញឲ្យបានច្បាស់លាស់គ្រប់ជំហានទាំងអស់នៃការផ្ដល់សម្អាងហេតុរបស់ខ្លួន លើការសម្រេចនិមួយៗដែលខ្លួនបានធ្វើ

---

[81] **E1/180.1** ប្រតិចារឹក, ១១ មេសា ២០១៣ ត្រង់ទំព័រទី១០៣។

[82] **E275/1** សេចក្ដីសម្រេចដែលរងការជំទាស់, ត្រង់កថាខណ្ឌទី២៣, កំណត់សម្គាល់ជើងទំព័រលេខ៤៧។

[83] **E275/1** សេចក្ដីសម្រេចដែលរងការជំទាស់, ត្រង់កថាខណ្ឌទី២៣។

[84] **E163/5/1/13** សេចក្ដីសម្រេចលើបណ្ដឹងសាទុក្ខភ្លាមៗរបស់សហព្រះរាជអាជ្ញាប្រឆាំងនឹងសេចក្ដីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងស្ដីពីវិសាលភាពនៃសំណុំរឿងលេខ ០០២/០១, ៨ កុម្ភៈ ២០១៣, ត្រង់កថាខណ្ឌទី៣៦។

នោះទេ"[85]។ យ៉ាងណាមិញនៅក្នុងវាក្យខណ្ឌ "ច្បាប់ជាធរមាន" នៃសេចក្តីសម្រេចរបស់ខ្លួន អង្គជំនុំជម្រះសាលាដំបូងបានបញ្ជាក់យ៉ាងច្បាស់នូវការយល់ដឹងរបស់ខ្លួនថាខ្លួន "ក៏ត្រូវតែពិចារណាឲ្យដឹងថាតើស្ថាប័នតុលាការដែលពាក់ព័ន្ធ បានបង្ហាញឲ្យឃើញនូវការព្យាយាមក្នុងការអនុវត្តកិច្ចដំណើរការនីតិវិធី ដែរឬអត់"[86]។ ជាការបន្ថែម នៅក្នុងកំណត់សម្គាល់នៃការសន្និដ្ឋានរបស់មេធាវីការពារក្តីដែលចោទថាមានការរំលោភសិទ្ធិជនជាប់ចោទនៅក្នុងការទទួលបានការជំនុំជម្រះក្តីដោយត្រឹមត្រូវ និងចម្លើយតបរបស់សហព្រះរាជអាជ្ញាអំពីការចោទប្រកាន់នៃការពន្យារពេលមិនត្រឹមត្រូវ[87] គេមានភ័ស្តុតាងបញ្ជាក់យ៉ាងច្បាស់ថា អង្គជំនុំជម្រះសាលាដំបូងមានការយល់ដឹងនៅក្នុងសេចក្តីពិចារណាទាំងឡាយដែលនឹងនាំឲ្យមាន "ការវាយតម្លៃពីការពន្យារពេលដែលអាចកើតមានចំពោះកិច្ចដំណើរការនីតិវិធី"[88] នៅក្នុងសេចក្តីសម្រេចថា "សវនាការជំនុំជម្រះក្នុងសំណុំរឿង០០២ បានដំណើរការទៅមុខយ៉ាងលឿនតាមដែលអាចធ្វើទៅបាន[89]។

៣៩- លើសពីនេះ មួយចំណែកធំនៃអំណះអំណាងរបស់មេធាវីការពារក្តី ទាក់ទងនឹងការពន្យារពេលនៅក្នុងអំឡុងនៃដំណាក់កាលស៊ើបសួរ ត្រូវបានចំណាយក្នុងការព្យាយាមតវ៉ាឡើងវិញទៅលើភាពអាចទទួលយកបាននៃភ័ស្តុតាងដែលខ្លួនបានដាក់ជូនអង្គជំនុំជម្រះសាលាដំបូងរួចហើយ ក៏ប៉ុន្តែអង្គជំនុំជម្រះសាលាដំបូងមិនបានទទួលយកទេ[90] ទោះបីជាសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងទាក់ទងនឹងការទទួលយកភ័ស្តុតាងនេះ មិនមែនជាកម្មវត្ថុនៃបណ្តឹងសាទុក្ខភ្លាមៗ[91] កុំថាឡើយភ័ស្តុតាងនិមួយៗ ឬជាកន្សោមពាក់ព័ន្ធនឹងបញ្ហាផ្សេងទៀតក៏ដោយ។ មេធាវីការពារក្តីស្វែងរកការតវ៉ាចំពោះសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូង ដែលបដិសេធលើសំណើរបស់មេធាវីការពារក្តី អនុលោមតាមវិធាន៨៧(៤) សុំដាក់នៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូងនូវសម្រង់នៃសៀវភៅ

[85] **E163/5/1/13** សេចក្តីសម្រេចលើបណ្តឹងសាទុក្ខភ្លាមៗរបស់សហព្រះរាជអាជ្ញាប្រឆាំងនឹងសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងស្តីពីវិសាលភាពនៃសំណុំរឿងលេខ ០០២/០១, ៨ កុម្ភៈ ២០១៣, ត្រង់កថាខណ្ឌទី៣៦។

[86] **E275/1** សេចក្តីសម្រេចដែលរងការជំទាស់, ត្រង់កថាខណ្ឌទី១៥។ សូមមើលផងដែរ E1/180.1 ប្រតិចារឹក, ១១ មេសា ២០១៣ ត្រង់ទំព័រទី១០១។

[87] **E275/1** សេចក្តីសម្រេចដែលរងការជំទាស់, ត្រង់កថាខណ្ឌទី៨, ១០។

[88] **E275/2/1** បណ្តឹងសាទុក្ខ, ត្រង់កថាខណ្ឌទី៥១។

[89] **E275/2/1** បណ្តឹងសាទុក្ខ, ត្រង់កថាខណ្ឌទី៤៩។

[90] **E275/2/1** បណ្តឹងសាទុក្ខ, ត្រង់កថាខណ្ឌទី៥២-៥៤។

[91] វិធាន១០៤(៤)។

របស់ Marcel Lemonde ដែលមានចំណងជើងថា *Un Juge Face Aux Khmer Rouge*[92]។ "សេចក្តីសម្រេចនានាដែលឋិតនៅក្រៅវិសាលភាពនៃវិធាន១០៤(៤)នៃវិធានផ្ទៃក្នុង អាចប្តឹងសាទុក្ខបាន បន្ទាប់ពីចេញសាលក្រមចុងក្រោយសិន" ហើយ "សេចក្តីសម្រេចផ្សេងទៀត [របស់អង្គជំនុំជម្រះតុលាការកំពូល] បានបដិសេធចោលប្រហាក់ប្រហែលគ្នានេះដែរនូវបណ្តឹងសាទុក្ខដែលមិនអាចទទួលយកបាន ពីព្រោះបណ្តឹងសាទុក្ខទាំងនោះមិនឋិតនៅក្នុងវិសាលភាពនៃវិធាន១០៤(៤) នៃវិធានផ្ទៃក្នុង"[93]។ អាស្រ័យហេតុនេះ សេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូង ស្តីពីភាពអាចទទួលយកបាននៃភ័ស្តុតាង មិនបើកផ្លូវឲ្យប្តឹងសាទុក្ខទេ ដូច្នេះការតវ៉ារបស់មេធាវីការពារក្តីគួរតែបដិសេធចោល។ នៅក្នុងករណីណាក៏ដោយ សេចក្តីសម្រេចនេះមានសម្អាងហេតុទាំងស្រុង អាស្រ័យដោយសារភាពយឺតយ៉ាវនៃពាក្យសុំឲ្យទទួលយកភ័ស្តុតាងថ្មីនេះ នៅក្នុងបរិបទនៃពាក្យសុំដាក់ឲ្យស្ថិតនៅក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការ[94]។

៤០- មេធាវីការពារក្តីតវ៉ាបន្ថែមទៀតថា អង្គជំនុំជម្រះសាលាដំបូងមានកំហុសចំពោះសេចក្តីសម្រេចរបស់ខ្លួន "ដែលថាជនជាប់ចោទមិនអាចព្យាករបាន ឬមិនប្រាកដពីរយៈពេលនៃសវនាការនេះ"[95]។ តាំងពីដើមដំបូងមក សហព្រះរាជអាជ្ញាប្រកាន់គោលជំហរថា ករណីទាំងឡាយដែលបានលើកយោងដោយមេធាវីការពារក្តី ជូនអង្គជំនុំជម្រះសាលាដំបូង ដើម្បីគាំទ្រចំពោះគោលការណ៍នេះ គឺ "មិនពាក់ព័ន្ធនឹងគោលបំណងបច្ចុប្បន្ននេះទេ" ដោយហេតុតែករណីទាំងនោះមានការពាក់ព័ន្ធនឹងបញ្ហានៃភាពប្រាកដប្រជាផ្លូវច្បាប់ ដែលជាបញ្ហាមួយមានវិវាទនៅក្នុងសំណុំរឿងនានានៅចំពោះមុខតុលាការសិទ្ធិមនុស្សអឺរ៉ុប ដែលបានលើកយោងនៅក្នុងពាក្យសុំដោះលែងដោយមេធាវីការពារក្តី[96]។ ក្នុងបណ្តឹងសាទុក្ខបន្ទាន់នេះ មេធាវីការពារក្តីមិនបានផ្តល់ករណីយុត្តិសាស្ត្រ*ណាមួយ* ដើម្បីគាំទ្រចំពោះភាពពាក់ព័ន្ធនៃ

---

[92] **E280/1** អ៊ីម៉ែលពី Roger Phillips យោង: ទម្រង់នៃចម្លើយតបទៅនឹងពាក្យសុំរបស់ ខៀវ សំផន អនុលោមតាមវិធាន៨៧(៤), ១៩ មេសា ២០១៣។

[93] **E154/1/1/4** សេចក្តីសម្រេចលើបណ្តឹងសាទុក្ខរបស់ អៀង សារី ប្រឆាំងនឹងសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងទាក់ទិននឹងការប្រាស្រ័យទាក់ទងការងារជាមួយតែភាគីម្ខាងរបស់មន្ត្រីច្បាប់ជាន់ខ្ពស់, ២៥ មេសា ២០១២, កថាខណ្ឌទី១២។

[94] សូមមើល សេចក្តីសន្និដ្ឋានរបស់សហព្រះរាជអាជ្ញាស្តីពីបញ្ហានេះ៖ **E1/180.1** ប្រតិចារឹក, ១១ មេសា ២០១៣ ត្រង់ទំព័រ៧០, ៧២-៧៥។

[95] **E275/1** សេចក្តីសម្រេចដែលរងការជំទាស់, ត្រង់កថាខណ្ឌទី២៣។ **E275/2/1** បណ្តឹងសាទុក្ខ, ត្រង់កថាខណ្ឌទី៥៨-៧០។

[96] **E1/180.1** ប្រតិចារឹក, ១១ មេសា ២០១៣ ត្រង់ទំព័រទី៩៩។

គោលការណ៍នេះទេ។ លើសពីនេះ ភាពអាចព្យាករបានចំពោះសាលក្រមក្នុងសំណុំរឿង០០២/០១[97] មិនអាចជាការវិវាទធ្ងន់ធ្ងរឡើយ ដូចដែលអង្គជំនុំជម្រះបានគូសបញ្ជាក់ជាច្រើនលើកជាច្រើនសារថា ខ្លួនមានបំណងបញ្ចប់ការជំនុំជម្រះនៅពេលអនាគតដ៏ខ្លីខាងមុខ។ ការណ៍នេះត្រូវបានបញ្ជាក់អះអាងឡើងវិញក្នុងពេលថ្មីៗបំផុត នៅក្នុងអនុស្សរណៈរបស់អង្គជំនុំជម្រះសាលាដំបូង នៅថ្ងៃសវនាការលើភ័ស្តុតាងចុងក្រោយក្នុងសំណុំរឿង០០២/០១ ដែលបានបង្ហាញពីគម្រោងសង្ខេបនៃដំណាក់កាលបញ្ចប់នៃសំណុំរឿង០០២/០១[98]។

៤១- ជាចុងក្រោយ មេធាវីការពារក្តីហាក់ដូចជាតវ៉ាថា អង្គជំនុំជម្រះសាលាដំបូងមានកំហុសមួយ តាមរយៈការច្រានចោលអំណះអំណាងរបស់មេធាវីការពារក្តីថា អាយុរបស់ជនជាប់ចោទគួរតែគាំទ្រចំពោះការដោះលែងជាបណ្តោះអាសន្នរបស់គាត់ អង្គជំនុំជម្រះសាលាដំបូងបានពិចារណាពីចំណុចនេះដោយខ្លួនឯងផ្ទាល់ ជាជាងស្រូបយកកត្តាដទៃមកលាយឡំ[99]។ អំណះអំណាងនេះ ឥតមានអង្គសេចក្តីប្រហាក់ប្រហែលគ្នាដែរ។ ដើម្បីផ្តល់នូវសេចក្តីសម្រេចមួយដែលមានសម្អាងហេតុ អង្គជំនុំជម្រះសាលាដំបូងបានលើកពីកត្តាជាច្រើនដោយឡែកៗពីគ្នា ប៉ុន្តែបានពិចារណាអំពីអាយុ រួមគ្នានឹងកត្តាពាក់ព័ន្ធដទៃទៀតក្នុងការធ្វើសេចក្តីសម្រេចរបស់ខ្លួន និងបានកំណត់ថា "កត្តាទាំងឡាយដែលជាយុត្តិកម្មក្នុងការបន្តការឃុំខ្លួនគាត់ មានទម្ងន់ធ្ងន់ជាងបញ្ហាបុគ្គល"[100]។

## គ. ការភាន់ច្រឡំរបស់អង្គជំនុំជម្រះសាលាដំបូងនៅក្នុងការកត់សម្គាល់ដែលថា ពុំមានការផ្លាស់កាលៈទេសៈ គឺមិនមានផលប៉ះពាល់

៤២- ការពិចារណារបស់អង្គជំនុំជម្រះសាលាដំបូង ចំពោះលក្ខខណ្ឌតម្រូវនៃវិធាន៨២(៤) ដែលថា ជនជាប់ចោទបង្ហាញឱ្យឃើញនូវការផ្លាស់ប្តូរកាលៈទេសៈ ចាប់ពីពាក្យសុំចុងក្រោយរបស់គាត់ គឺមាន

[97] **E288** អនុស្សរណៈរបស់អង្គជំនុំជម្រះសាលាដំបូងស្តីពី៖ ការជូនដំណឹងអំពីសវនាការដែលនៅសេសសល់ មុនពេលបិទកិច្ចដំណើរការនីតិវិធីសវនាការលើភស្តុតាងនៅក្នុងសំណុំរឿង០០២/០១ និងការកំណត់កាលបរិច្ឆេទនៃកិច្ចប្រជុំរៀបចំសវនាការលើកចុងក្រោយសម្រាប់ថ្ងៃទី១៣ ខែមិថុនា ឆ្នាំ២០១៣, ៣១ ឧសភា ២០១៣។

[98] *សូមមើល* **E288** អនុស្សរណៈរបស់អង្គជំនុំជម្រះសាលាដំបូងស្តីពី៖ ការជូនដំណឹងអំពីសវនាការដែលនៅសេសសល់ មុនពេលបិទកិច្ចដំណើរការនីតិវិធីសវនាការលើភស្តុតាងនៅក្នុងសំណុំរឿង០០២/០១ និងការកំណត់កាលបរិច្ឆេទនៃកិច្ចប្រជុំរៀបចំសវនាការលើកចុងក្រោយសម្រាប់ថ្ងៃទី១៣ ខែមិថុនា ឆ្នាំ២០១៣, ៣១ ឧសភា ២០១៣, ត្រង់កថាខណ្ឌទី៨-១០។

[99] **E275/2/1** បណ្តឹងសាទុក្ខ, ត្រង់កថាខណ្ឌទី៧១-៧៤។

[100] **E275/1** សេចក្តីសម្រេចដែលរងការជំទាស់, ត្រង់កថាខណ្ឌទី២៣។

ការភាន់ច្រឡំ ដូចមេធាវីការពារក្តីសន្និដ្ឋាន។ ទោះបីវិធាន៨២(៤) អាចអនុវត្តបានជាធម្មតាក្តី ក៏មេធាវីការពារក្តីត្រូវបានអនុញ្ញាតឱ្យរួចផុតពីលក្ខខណ្ឌតម្រូវនេះ ទុកដូចជាដំណោះស្រាយមួយចំពោះកង្វះនូវការជូនដំណឹងគ្រប់គ្រាន់ដើម្បីរៀបចំសេចក្តីសន្និដ្ឋាន តាមវិធាន៦៣(៣) សម្រាប់សវនាការនានានៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង នៅក្នុងអំឡុងពេលនៃពាក្យសុំមុនៗ[101]។

៤៣- យ៉ាងណាមិញ ការភាន់ច្រឡំនេះមិនធ្វើឱ្យមានការខូចខាត ឬប៉ះពាល់ប្រយោជន៍ដល់ជនជាប់ចោទទេ ហើយក៏មិនធ្វើឱ្យមោឃភាពចំពោះសេចក្តីសម្រេចនេះដែរ។ ការផ្តល់សម្អាងហេតុរបស់អង្គជំនុំជម្រះសាលាដំបូងបង្ហាញឱ្យឃើញថា ខ្លួនបានបំពេញនូវការត្រួតពិនិត្យ*សាជាថ្មី* លើគ្រប់កាលៈទេសៈទាំងអស់ដើម្បីគាំទ្រ ឬប្រឆាំងនឹងការបន្តការឃុំខ្លួនជនជាប់ចោទ។ ហេតុដូច្នេះ ទោះបីជាអង្គជំនុំជម្រះសាលាដំបូងបានបញ្ជាក់យ៉ាងច្បាស់ថា មិនដាក់លក្ខខណ្ឌឱ្យមេធាវីការពារក្តីត្រូវបង្ហាញពីការផ្លាស់ប្តូរកាលៈទេសៈណាមួយក៏ដោយ ក៏លទ្ធផលនៃសេចក្តីសម្រេចដែលរងការជំទាស់ ក៏នៅតែដូចគ្នាដដែល។ ដូច្នេះ កំហុសនេះមិនធ្វើឱ្យមោឃៈសេចក្តីសម្រេចនេះបានទេ។

៤៤- វិធាន១០៤(១)(ក) ចែងថា អង្គជំនុំជម្រះមានយុត្តាធិការលើបណ្តឹងសាទុក្ខចំពោះ "កំហុសលើអង្គច្បាប់ ដែលនាំឱ្យមោឃៈសាលក្រមលើអង្គសេចក្តី ឬសេចក្តីសម្រេចនោះ"។ វិធាន១០៥(២) ចែងអំពីលក្ខខណ្ឌតម្រូវសម្រាប់ការទទួលយកបណ្តឹងសាទុក្ខ ហើយបើមានភាពជាប់ជំពាក់ណាមួយ បទដ្ឋាននៃការត្រួតពិនិត្យជាធរមាន ចែងថាមេធាវីការពារក្តីត្រូវ "បញ្ជាក់ពីកំហុសអង្គច្បាប់ និងត្រូវបង្ហាញថាកំហុសនោះបណ្តាលឱ្យសេចក្តីសម្រេចមានមោឃភាព"។ លក្ខខណ្ឌតម្រូវទាំងពីរ គឺបន្ថែមកម្លាំងឱ្យគ្នាទៅវិញទៅមក។ ដើម្បីបំពេញបាននូវបទដ្ឋាននេះ ម្ចាស់បណ្តឹងសាទុក្ខមិនមែនតែកំណត់អត្តសញ្ញាណកំហុសដែលខ្លួនបានចោទប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងបង្ហាញថាកំហុសនោះបណ្តាលឱ្យមានមោឃភាពដល់សេចក្តីសម្រេចដែលរងការជំទាស់នេះ។ អង្គជំនុំជម្រះបានទទួលស្គាល់ថា ត្រូវមានភ័ស្តុតាងខ្លះបញ្ជាក់ការខូចខាត ឬប៉ះពាល់ប្រយោជន៍ចំពោះសិទ្ធិជនជាប់ចោទ ដែលជាកំហុសអង្គច្បាប់ដែលនាំឱ្យមោឃៈសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូង និងសមទទួលបានដំណោះស្រាយ[102]។

---

[101] សូមមើល **E50/3/1/4** បណ្តឹងសាទុក្ខភ្លាមៗ, ត្រង់កថាខណ្ឌទី៥១។

[102] *សូមមើល* **E176/2/1/4** សេចក្តីសម្រេចលើបណ្តឹងសាទុក្ខរបស់ នួន ជា ប្រឆាំងនឹងសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងលើសំណើសុំឱ្យចាត់ការជាបន្ទាន់ តាមវិធាន ៣៥ នៃវិធានផ្ទៃក្នុង, ១៤ កញ្ញា ២០១២ ត្រង់កថាខណ្ឌទី២៩។

៤៥- យុត្តិសាស្ត្រពីបណ្ដាតុលាការ*ពិសេស*នានា ក៏គាំទ្រចំពោះគោលការណ៍ដែលថា សេចក្ដីសម្រេចមិនមានមោឃៈដោយសារកំហុសមានផលប៉ះពាល់នោះឡើយ។ អង្គជំនុំជម្រះសាលាឧទ្ធរណ៍នៃតុលាការ ICTY បានធ្វើការប្រកាសស្របគ្នាថា បើគ្មានភស្តុតាងបញ្ជាក់ពីការខូចប្រយោជន៍ទេ ទោះបីជាមានកំហុសអង្គច្បាប់ជាក់ស្ដែងក៏ដោយ នឹងមិនចាត់ទុកថាធ្វើឱ្យមានមោឃភាពចំពោះសេចក្ដីសម្រេចដែលរងការជំទាស់ណាមួយដែរ[103]។

៤៦- ក្នុងខ្លឹមសារនេះ មេធាវីការពារក្ដីខកខានមិនបានបញ្ជាក់ ឬសូម្បីតែកំណត់អត្តសញ្ញាណ នូវផលប៉ះពាល់ ឬការខូចប្រយោជន៍ណាមួយដែលបណ្ដាលមកពីកំហុសដែលបានលើកឡើង យោងតាមវិធាន ៨២(៤) អាចនាំឱ្យមោឃៈសេចក្ដីសម្រេច[104]ឡើយ។ ការបដិសេធរបស់សេចក្ដីសម្រេចដែលរងការជំទាស់លើពាក្យសុំរបស់ជនជាប់ចោទ មិនមែនស្ថិតនៅលើការអនុវត្តដោយមានកំហុសនៃវិធាន៨២ (៤)ទេ។ តាមពិត វិធាន៨២(៤) ហាក់ដូចជាគ្មានទម្ងន់អ្វីបន្តិចសោះចំពោះការផ្ដល់សម្អាងហេតុរបស់អង្គជំនុំជម្រះសាលាដំបូង។ សូម្បីតែវិធាន និងលក្ខខណ្ឌតម្រូវផ្សេងៗនៃវិធានទាំងនេះ មិនបានលើកយោងច្រើនដែរ រហូតទាល់តែមានការប្រកាសសេចក្ដីសម្រេចជាចុងក្រោយ និងបន្ទាប់មកគ្រាន់តែមានសេចក្ដីសង្ខេបប៉ុណ្ណោះ[105]។

៤៧- អាស្រ័យហេតុនេះ នៅពេលអង្គជំនុំជម្រះសាលាដំបូងមានកំហុសអង្គច្បាប់ ដោយការយោងទៅរកវិធាន៨២(៤) កំហុសនេះមិនមោឃៈសេចក្ដីសម្រេចនេះបានទេ។ វាមិនបណ្ដាលឱ្យមានផលប៉ះពាល់ ឬការខូចខាតដល់សិទ្ធិរបស់ជនជាប់ចោទឡើយ ហើយ ដូច្នេះមិនឆ្លើយតបទៅនឹងបទដ្ឋាន ក្នុងការសមទទួលបានដំណោះស្រាយឡើយ។

---

[103] *សូមមើល រដ្ឋអាជ្ញា ទល់នឹង Galic,* សំណុំរឿងលេខ: IT-98-29-A, សាលដីកា (អង្គជំនុំជម្រះសាលាឧទ្ធរណ៍នៃតុលាការ ICTY), ៣០ វិច្ឆិកា ២០០៦ ត្រង់កថាខណ្ឌទី២១។ *សូមមើលផងដែរ រដ្ឋអាជ្ញា ទល់នឹង Blaskic,* សំណុំរឿងលេខ: IT-95-14-A, សាលដីកា (អង្គជំនុំជម្រះសាលាឧទ្ធរណ៍នៃតុលាការ ICTY), ២៩ កក្កដា ២០០៤ ត្រង់កថាខណ្ឌទី២៩៩។ *រដ្ឋអាជ្ញា ទល់នឹង Haradinaj,* សំណុំរឿងលេខ: IT-04-84-A, សាលដីកា (អង្គជំនុំជម្រះសាលាឧទ្ធរណ៍នៃតុលាការ ICTY), ១៩ កក្កដា ២០១០ ត្រង់កថាខណ្ឌទី១៧។

[104] **E275/2/1** បណ្ដឹងសាទុក្ខ, ត្រង់កថាខណ្ឌទី៧៥-៧៨។

[105] **E275/1** សេចក្ដីសម្រេចដែលរងការជំទាស់, ត្រង់កថាខណ្ឌទី២៣។

## VII. សេចក្តីសន្និដ្ឋាន

៤៨- អាស្រ័យដូចមូលហេតុដែលបានជម្រាបជូនខាងលើ សហព្រះរាជអាជ្ញាស្នើឲ្យអង្គជំនុំជម្រះតុលាការកំពូល **បដិសេធចោល** បណ្តឹងសាទុក្ខនេះទាំងមូល៕

| កាលបរិច្ឆេទ | ឈ្មោះ | ទីកន្លែង | ហត្ថលេខា |
|---|---|---|---|
| ថ្ងៃទី៦ ខែមិថុនា ឆ្នាំ២០១៣ | **លោកស្រី ជា លាង** សហព្រះរាជអាជ្ញា | ភ្នំពេញ | |
| | **លោក** Andrew CAYLEY សហព្រះរាជអាជ្ញា | | |